ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្ដីព្រាង

ក្រសួងមហាផ្ទៃ

# របាយការណ៍
# ស្ដីពី
# សមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
# អាណត្តិទី៥ សម្រាប់ឆ្នាំ២០២២-២០២៥

ពុទ្ធសករាជ២៥៧០ ឆ្នាំ២០២៦

# មាតិកានុក្រម

**១-សេចក្តីផ្តើម** ............ ១
**២-សមិទ្ធិផលការងារចម្បងៗ** ............ ២
២.១-គោលនយោបាយ និងក្របខណ្ឌគតិយុត្ត ............ ២
២.២-ដីកា សេចក្តីសម្រេច និងលិខិតនានា ............ ៤
២.៣-ក្រុមប្រឹក្សា និងបុគ្គលិករបស់រដ្ឋបាលឃុំ សង្កាត់ ............ ៥
២.៤-កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ............ ៧
២.៥-គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ និងគណៈកម្មការនានា ............ ៧
២.៦-ការកសាងនិងការអនុវត្តផែនអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់រដ្ឋបាលឃុំ សង្កាត់ ............ ៨
២.៧-ថវិកាឃុំ សង្កាត់ ២០២២-២០២៦ ............ ៩
២.៧.១ ប្រភពពីមូលនិធិឃុំ សង្កាត់ ............ ៩
២.៧.២ ប្រភពពីថវិកាផ្សេងៗទៀត ............ ១១
២.៧.៣ ថវិកាសរុបឃុំ សង្កាត់ ............ ១១
២.៨-ការអនុវត្តគម្រោងរបស់រដ្ឋបាលឃុំ សង្កាត់ ............ ១៣
២.៩-ស្ថានភាពអគាររដ្ឋបាលឃុំ សង្កាត់ ............ ១៦
២.១០-ការងារបង្កើតភូមិ និងថ្នាក់ដឹកនាំភូមិ ............ ១៧
២.១១-ការងារផ្តល់សេវាសាធារណៈ ............ ១៨
២.១១.១ ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ ............ ១៨
២.១១.២ ការផ្តល់សេវាផ្សេងៗ ............ ២១
២.១២-ការសម្រុះសម្រួលនិងការដោះស្រាយវិវាទនៅមូលដ្ឋាន ............ ២២
២.១៣-ការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការចុះឈ្មោះអ្នកបោះឆ្នោត ............ ២២
២.១៤-ការកសាងសមត្ថភាពនិងការបណ្តុះបណ្តាល ............ ២៣
២.១៥ ការងារឌីជីថល ............ ២៤
២.១៦-ការងារគណនេយ្យភាពសង្គម ............ ២៤
២.១៧-ការអនុវត្តគោនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ............ ២៥
២.១៨-សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ............ ២៥
**៣-បញ្ហាប្រឈម និងអនុសាសន៍** ............ ២៦
**៤-សេចក្តីសន្និដ្ឋាន** ............ ២៩

ថ្ងៃ.........................ខែ..........ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី...........ខែ............ឆ្នាំ២០២៦

# របាយការណ៍
# ស្តីពី
# ការបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
# អាណត្តិទី៥ ឆ្នាំ២០២២-២០២៥

## ១-សេចក្តីផ្តើម

ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាត្រូវបានចាប់ផ្តើមនៅកម្រិតឃុំ សង្កាត់ តាមរយៈការដាក់ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាឆ្នាំ២០០១។ ផ្អែកតាមច្បាប់ទាំងពីរនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោត ដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចឃុំ សង្កាត់នីមួយៗ ជាលើកដំបូងនាឆ្នាំ២០០២ ដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ព្រមទាំងធនធាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ចាប់តាំងពីឆ្នាំ២០០២ដល់ឆ្នាំ២០២៥នេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានរៀបចំឡើងចំនួនបួនអាណត្តិរួចមកហើយ គឺអាណត្តិទី១ត្រូវបានធ្វើឡើងនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០២ មានឃុំ សង្កាត់ចំនួន**១.៦២១** សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន**១១.២៦១**រូប អាណត្តិទី២ត្រូវបានធ្វើឡើងនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៧ មានឃុំ សង្កាត់ចំនួន**១.៦៣៣** សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន **១១.៣៥៣**រូប អាណត្តិទី៣ត្រូវបានធ្វើឡើងនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២ មានឃុំ សង្កាត់ចំនួន **១.៦៣៣** សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន**១១.៤៥៩**រូប អាណត្តិទី៤ត្រូវបានប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ មានឃុំ សង្កាត់ចំនួន**១.៦៤៦** និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន**១១.៥៧២**រូប និងអាណត្តិទី៥ ត្រូវបានប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ មានឃុំ សង្កាត់ចំនួន**១.៦៥២** និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន**១១.៦២២នាក់**។

ការរៀបចំការបោះឆ្នោតជាទៀងទាត់នេះ បានពង្រឹងនូវនិរន្តរភាព ភាពស្របច្បាប់ និងភាពជាតំណាងរបស់រដ្ឋបាលមូលដ្ឋាន ព្រមទាំងផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្តសិទ្ធិអំណាចនិងស្វ័យភាពក្នុងការដឹកនាំ គ្រប់គ្រង ការចាត់ចែងថវិកា និងការកសាងសមិទ្ធផលជូនសង្គមជាតិកាន់តែរឹងមាំ។

ផ្អែកតាមមាត្រា៤២ មាត្រា៤៣ និងមាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទ គឺទី១)-បម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ច លើការរៀបចំនិងការចាត់ចែងសេវាសាធារណៈចាំបាច់សំខាន់ៗ ដូចជាការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន

ការថែរក្សាបរិស្ថាន ធនធានធម្មជាតិ និងការជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន សំដៅលើកកម្ពស់ជីវភាពប្រជាជន និងទី២)-បម្រើជាភ្នាក់ងារតំណាងរដ្ឋ ដែលបានកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋានពាក់ព័ន្ធ។ ក្រៅពីតួនាទីសំខាន់ៗនេះ រដ្ឋបាលឃុំ សង្កាត់ ក៏មានតួនាទីផ្សេងៗទៀតតាមការផ្ទេរមុខងារចាំបាច់មួយចំនួនពីក្រសួង ស្ថាប័នជាតិ ស្របតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ក្នុងស្មារតីនេះ ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងអាណត្តិនីមួយៗកន្លងមកនេះ បានខិតខំប្រែងបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងលិខិតបទដ្ឋាន ដែលបានកំណត់ នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅមូលដ្ឋាន សំដៅរួមចំណែកកែលម្អជីវភាពប្រជាពលរដ្ឋ និងកាត់បន្ថយនៅភាពក្រីក្រ តាមរយៈការអនុវត្តគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគម្រោងមិនមែនហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅមូលដ្ឋាន និង ការផ្តល់សេវាសាធារណៈផ្សេងៗទៀត ប្រកបដោយគណនេយ្យភាព ឆ្លើយតប និងបរិយាបន្ន។

ដោយឡែក ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥នេះ គឺជាអាណត្តិមួយ ដែលស្ថិតក្នុងដំណាក់កាលនៃ ការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ (២០២១-២០៣០) និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែលដឹកនាំដោយ **សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងក៏ជាអាណត្តិមួយ ដែលស្ថិតក្នុងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយថ្មីទៀត ដែលព្រះរាជាណាចក្រកម្ពុជាបានរងនូវសង្គ្រាមឈ្លានពានទឹកដី ពីសំណាក់ភាគីថៃតាំងពីខែកក្កដា ឆ្នាំ២០២៥ និងកំពុងអូសបន្លាយដល់បច្ចុប្បន្ននេះ។ សកម្មភាពឈ្លានពាននេះបានបំផ្លាញនូវលំនៅដ្ឋាន អគារ ស្ថាន ផ្លូវថ្នល់ ស្រែនិងចំការ ទីផ្សារ និងប្រាសាទបុរាណ ព្រមទាំងបង្កលំបាក និងអសន្តិសុខដល់ប្រជាជន និងដំណើការរបស់រដ្ឋបាលឃុំ សង្កាត់។ ការណ៍នេះ បានតម្រូវឱ្យរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន រដ្ឋបាល ថ្នាក់ក្រោមជាតិ រួមទាំងរដ្ឋបាលឃុំ សង្កាត់ ពិសេសរដ្ឋបាលឃុំ សង្កាត់ នៅតាមព្រំដែនកម្ពុជា-ថៃ បង្កើន សកម្មភាពរបស់ខ្លួន នៅក្នុងការងារសង្គ្រោះនិងគាំទ្រដល់ប្រជាជននូវចំណីអាហារ សម្លៀកបំពាក់ ការថែទាំសុខភាព និងការថែរក្សានូវសណ្តាប់ធ្នាប់ដល់ប្រជាជន ដែលត្រូវបានជម្លៀសចេញពីតំបន់ឈ្លានពានពី ប្រទេសថៃ។

ផ្អែកមូលដ្ឋានដូចបានរៀបរាប់ខាងលើនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិទី៥ បានបង្កើននូវការ យកចិត្តទុកខ្ពស់នៅក្នុងការអនុវត្តតួនាទី ភារកិច្ច និងមុខងារដែលបានផ្ទេរមកឱ្យរដ្ឋបាលឃុំ សង្កាត់ ដោយ មានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងសម្រេចបាននូវសមិទ្ធផល សំខាន់ៗ ដែលរួមមាន៖

## ២-សមិទ្ធិផលការងារចម្បងៗ

### ២.១-គោលនយោបាយ និងក្របខណ្ឌគតិយុត្ត

ចាប់ពីឆ្នាំ២០០២ដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា ក្រសួង ស្ថាប័ននានា របស់រាជរដ្ឋាភិបាល បានដាក់ចេញនូវច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានប្រមាណជិត ៦០០ ដើម្បីគាំទ្រ និងលើកកម្ពស់ការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ការអនុវត្តគោលនយោបាយនេះ ត្រូវបានដឹកនាំ និងសម្របសម្រួលដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលហៅកាត់ថា (គ.ជ.អ.ប.) និងមានការចូលរួមអនុវត្តពីក្រសួង

ស្ថាប័នពាក់ព័ន្ធជាច្រើនទៀត ដែលក្នុងនោះក៏មានក្រសួងមហាផ្ទៃផងដែរ ដែលបានដើរតួនាទីចម្បងនៅក្នុងការអនុវត្តគោលនយោបាយនេះ។

ដោយឡែក នៅក្នុងអាណត្តិទី៥ នៃក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគិតត្រឹមឆ្នាំ២០២២ដល់ឆ្នាំ២០២៥ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ចំនួន ៥៤ លិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីគាំទ្រដល់ការអនុវត្តតួនាទី និងភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់ឱ្យកាន់តែមានប្រសិទ្ធភាព គណនេយ្យភាព ឆ្លើយតប និងបរិយាបន្ន ដូចមានបង្ហាញនៅក្នុង **ឧបសម្ពន្ធ១** នៃរបាយការណ៍នេះ។ ខាងក្រោមនេះគឺជាច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួន ដែលបានដាក់ចេញឱ្យអនុវត្តចាប់ពីឆ្នាំ២០២២-២០២៥ ដែលរួមមានដូចជា៖

- ព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ២០២៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- អនុក្រឹត្យលេខ១៥៣ អនក្រ.បក. ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់
- អនុក្រឹត្យលេខ១៥៤ អនក្រ.បក. ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន
- អនុក្រឹត្យលេខ៨៤ អនក្រ.បក. ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ ស្តីពីការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យលេខ២៤៩ អនក្រ.បក. ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកំណត់អត្រាចែករំលែកពីសេវាសាធារណៈ និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋពីរដ្ឋបាលថ្នាក់ជាតិជូនជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ២៨០ អនក្រ.បក. ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការគោលការណ៍និងបទបញ្ញត្តិនៃការកំណត់លេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិភាតរភាព
- ប្រកាសលេខ១៨០ សហវ.ប្រក.អហក. ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- សារាចរអន្តរក្រសួងលេខ០០៧ សហវ-សរ.អហក. ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសរវាសង្គម និងអនាម័យ បរិស្ថាន និងមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់
- សេចក្តីណែនាំលេខ០៤៥ ស.ណ.ន. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការជ្រើសរើសតំណាងយុវជនចូលរួមជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

- សេចក្តីណែនាំលេខ០៣៧ ស.ណ.ន. ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការពង្រឹងចលនាប្រជាការពារ
- សេចក្តីណែនាំលេខ៥៨ អយក-ស.ណ.ន. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពី ការដំណើរការគ្រឹះស្ថានមត្តេយ្យសិក្សានិងសេវាអប់រំកុមារតូច ឆ្នាំ២០២៣-២០២៤ ក្នុងក្របខណ្ឌស្តង់ដាសាលារៀនគំរូ
- សេចក្តីណែនាំលេខ០០៦ ស.ណ.ន. ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទនិងនីតិនៃការកែតម្រូវទិន្នន័យនិងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន
- សេចក្តីសម្រេចលេខ០០៩ ស.ស.រ./គ.ជ.អ.ប. ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំប្រតិបត្តិស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់អ្នកផ្តត់ផ្គង់

### ២.២-ដីកា សេចក្តីសម្រេច និងលិខិតនានា

ក្នុងសិទ្ធិអំណាចនិងដែនសមត្ថកិច្ចរបស់ខ្លួន រដ្ឋបាលឃុំ សង្កាត់មានតួនាទីបម្រើផលប្រយោជន៍ប្រជាជនទូទៅក្នុងឃុំ សង្កាត់ ដោយស្មើភាពមិនរើសអើងក្នុងការគ្រប់គ្រងលើកិច្ចការនានានៃក្របខណ្ឌតួនាទីនិងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ឃុំ សង្កាត់នីមួយៗ។ នៅក្នុងអាណត្តិទី៥នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ បានប្រើប្រាស់អំណាចបញ្ញត្តិស្របតាមច្បាប់ ដោយបានដាក់ចេញនូវដីកាចំនួន ១១.៥៨៦ ដីកាដែលរួមមានដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដីកាកំណត់តារាងតម្លៃសេវារដ្ឋបាលឃុំ សង្កាត់ ដីកាស្តីពីការបង្កើតមត្តេយ្យសិក្សាសហគមន៍ និងដីកាស្តីពីការតែងតាំងជំនួយការហិរញ្ញវត្ថុឃុំ សង្កាត់ជាដើម។

ក្រៅពីដីកា រដ្ឋបាលឃុំ សង្កាត់ក៏បានដាក់ចេញនូវសេចក្តីសម្រេច និងលិខិតនានាសម្រាប់អនុវត្តដីកា និងសម្រាប់ចាត់ចែងការងាររដ្ឋបាល និងការគ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងសិទ្ធិអំណាចក្នុងរង្វង់ដែនដីរដ្ឋបាលឃុំ សង្កាត់នីមួយៗ សរុបចំនួន **៤.៣១០.៩៤៧** ។ សូមពិនិត្យលម្អិតក្នុងតារាង ២.១ ខាងក្រោម៖

**តារាងទី២.១៖ ចំនួនដីកា សេចក្តីសម្រេច និងលិខិតនានា**

| ល.រ. | លិខិតបទដ្ឋាន | ចំនួនលិខិតបទដ្ឋាន | | | | សរុប |
|---|---|---|---|---|---|---|
| | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | |
| ១ | លិខិតចូល | 157,735 | 209,120 | 220,756 | 232,872 | 820,483 |
| ២ | ដីកា ដែលបានដាក់ចេញ | 3,154 | 2,695 | 2,842 | 2,895 | 11,586 |
| ៣ | សេចក្តីសម្រេចដែលបានដាក់ចេញ | 24,637 | 20,585 | 18,931 | 20,805 | 84,958 |
| ៤ | លិខិតរដ្ឋបាលដែលបានដាក់ចេញ(មិនរាប់បញ្ចូលលិខិតបញ្ជាក់នានាឡើយ) | 739,720 | 728,829 | 985,993 | 920,761 | 3,260,684 |

## ២.៣-ក្រុមប្រឹក្សា និងបុគ្គលិករបស់រដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រៅពីក្រុមប្រឹក្សាដែលកើតឡើងពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានចំនួនពី ៥រូប ដល់ ១១រូប អាស្រ័យទៅតាមកត្តាប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់ឃុំ សង្កាត់នីមួយៗ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏មានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលមួយរូប ដែលជាមន្ត្រីក្រសួងមហាផ្ទៃ ធ្វើជាស្មៀនឃុំ សង្កាត់។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌ ដើម្បីជួយកិច្ចការរបស់ខ្លួន និងការចាំបាច់នានាស្របតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃលេខ០៥៥ ស.ណ.ន. ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ស្តីពីនីតិវិធីនៃការជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ និងប្រកាសអន្តរក្រសួងរវាងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ០០២ សហវ-ប្រក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ ស្តីពីការជ្រើសរើស និងការកំណត់តួនាទី និងភារកិច្ចរបស់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់។

នៅក្នុងអាណត្តិទី៥ នេះ មានគណបក្សចំនួនចំនួន១៧ បានចូលរួមនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលបានប្រព្រឹត្តទៅក្នុងបរិយាកាសមួយប្រកបដោយសុខសន្តិភាព សេរី ត្រឹមត្រូវ និងយុត្តិធម៌។ ជាលទ្ធផល មានគណបក្សចំនួន៩ បានទទួលអាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិនេះ ដែលរួមមានគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សភ្លើងទាន គណបក្សខ្មែររួបរួមជាតិ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន គណបក្សខ្មែរស្រឡាញ់ជាតិ គណបក្សយុវជន និងគណបក្សកម្ពុជានិយម ព្រមទាំងត្រូវបានប្រកាសសុពលភាពឱ្យចូលកាន់តំណែងស្របតាមច្បាប់និងលិខិតបទដ្ឋានជាធរមាន។ ផ្អែកលើលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ខាងលើនេះ ពិតជាបានបង្ហាញនូវការប្តេជ្ញាចិត្តដ៏ច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការលើកកម្ពស់ប្រជាធិបតេយ្យ សេរីពហុបក្ស នៅថ្នាក់មូលដ្ឋាន ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកដល់ការអភិវឌ្ឍនៅមូលដ្ឋានប្រកបដោយចីរភាព។

ម្យ៉ាងវិញទៀត ក្នុងអាណត្តិទី៥ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានប្រកាសចូលកាន់តំណែងមានចំនួនសរុប ១១.៦២២នាក់ ដែលក្នុងនោះមានស្ត្រីចំនួន២.៥៩២ ស្មើនឹងប្រមាណ២២ភាគរយ ក្នុងនោះមេឃុំចំនួន១.៣៨៥រូប ស្រីចំនួន ១៣៩រូប(១០%) ចៅសង្កាត់ចំនួន ២៦៧រូប ស្រីចំនួន ៣៤រូប(១២,៧%)។ ដោយឡែក ជំទប់ទី១ មានចំនួនសរុប ១.៣៨៥រូប ស្រីចំនួន ២៧៣រូប (១៩,៧%) ជំទប់ទី២ចំនួន ១.៣៨៥រូប ស្រីចំនួន ១៦០រូប (១១.៥%) ចៅសង្កាត់រងទី១ចំនួន ២៦៧រូប ស្រីចំនួន ៦៧រូប (២៥%) ចៅសង្កាត់រងទី២ចំនួន ២៦៧រូប ស្រីចំនួន ៣៩រូប (១៤,៦%) និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៦.៦៦៦រូប ស្រី ចំនួន១.៨៥៧រូប (២៨%)។

ជាមួយគ្នានេះ ក្នុងអាណត្តិទី៥ ឆ្នាំ២០២២-២០២៥ នៃក្រុមប្រឹក្សាឃុំ សង្កាត់នេះ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្លាស់ប្តូរសរុបចំនួន ៧៣៥រូប(ស្រី១៥៨រូប) ដោយសារសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួនបានសុំលាឈប់ពីតំណែង ការបាត់បង់កាយសម្បទា ការទទួលមរណភាព ការផ្តន្ទាទោសដោយសាលក្រមរបស់តុលាការ និងការបណ្តេញចេញពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងសេចក្តីណែនាំលេខ០១១ ស.ណ.ន. ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

ក្រៅពីចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដូចបានរៀបរាប់ខាងលើ នៅក្នុងអាណត្តិទី៥នេះ ក៏មានស្មៀនឃុំ សង្កាត់មានចំនួនសរុប ចំនួន ១.៦៥២រូប ក្នុងនោះស្រីមានចំនួន ៣២៦រូប (២០%) និងមន្ត្រីកិច្ច-សន្យាសរុបចំនួន ៨.០៤៥ រូប ក្នុងនោះ ជំនួយការរដ្ឋបាលមានចំនួន ២.៨៦៣រូប ស្រីចំនួន ១.៣៩២ រូប (៤៩%) ជំនួយការហិរញ្ញវត្ថុ ១.៦៥២ ស្រីចំនួន ៣២៦ (២០%) គ្រូមតេយ្យសហគមន៍ ចំនួន ៣.៣៤៨ រូប ស្រី ២.៨៩៦ រូប (៨៦%) និងជំនួយការសេវាសង្គមនិងអនាម័យបរិស្ថានចំនួន ១៨២ ស្រីចំនួន ១៣៦ រូប (៧៥%)។

ការបង្កើតមុខតំណែងជំនួយការទាំងនេះ បានឆ្លុះបញ្ចាំងពីការប្រែក្លាយរដ្ឋបាលឃុំ សង្កាត់ ពី រដ្ឋបាលសាមញ្ញ ទៅជារដ្ឋបាលមូលដ្ឋានដែលទាមទារនូវជំនាញបច្ចេកទេសចម្រុះ និងមានរចនាសម្ព័ន្ធការងារកាន់តែរឹងមាំនិងទូលំទូលាយ។

**តារាង២.២៖ ចំនួនក្រុមប្រឹក្សា និងបុគ្គលិក**

| ល.រ. | ការបរិយាយ | សរុប | ស្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | 9,287 | 2,249 | |
| ២ | មេឃុំ ចៅសង្កាត់ | 1,652 | 185 | |
| ៣ | ជំទប់ទី១ ចៅសង្កាត់រងទី១ | 1,652 | 341 | |
| ៤ | ជំទប់ទី២ ចៅសង្កាត់រងទី២ | 1,652 | 196 | |
| ៥ | ចំនួនសមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ(មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិក) បានចេញប្រកាសផ្លូវការ | 735 | 158 | |
| ៦ | ស្មៀនឃុំ សង្កាត់ | 1,652 | 326 | |
| ៧ | **បុគ្គលិកក្រៅក្របខណ្ឌរដ្ឋ(បុគ្គលិកកិច្ចសន្យា)** | | | |
| | - ជំនួយការរដ្ឋបាល | 2,863 | 1,392 | |
| | - ជំនួយការហិរញ្ញវត្ថុ | 1,652 | 998 | |
| | - គ្រូមត្តេយ្យសិក្សាសហគមន៍ | 3,298 | 2,896 | |
| | - ជំនួយការសេវាសង្គម និងអនាម័យបរិស្ថាន | 182 | 136 | |

ដើម្បីលើកកម្ពស់និងបង្កើនប្រសិទ្ធភាពការងារ និងការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយតម្លា-ភាពនិងគណនេយ្យភាព រាជរដ្ឋាភិបាលបានសម្រេចដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជាបន្តបន្ទាប់ដល់ក្រុម-ប្រឹក្សាឃុំ សង្កាត់។ តាមរយៈអនុក្រឹត្យលេខ៣១០ អនក្រ.បក. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ រួមមាន៖ មេឃុំ ចៅសង្កាត់ទទួលបានចំនួន ១.៣៤៥.០០០រៀល ជំទប់ឬចៅសង្កាត់រងទទួលបានចំនួន ១.០០៥.០០០រៀល ចំណែកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបានចំនួន ៨៩៥.០០០រៀល។

### ២.៤-កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

ផ្អែកតាមមាត្រា២១នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ។ ជារៀងរាល់ឆ្នាំក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗបានអនុម័តប្រតិទិនកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយបានផ្សព្វផ្សាយជូនដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ចម្លងជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបិទនៅក្តារខៀនព័ត៌មាននៃសាលាឃុំ សង្កាត់សាមីទៀតផង។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាកិច្ចការដ៏មានសារៈសំខាន់ក្នុងការត្រួតពិនិត្យ និងសម្រេចកិច្ចការនានា ព្រមទាំងជាយន្តការពិគ្រោះយោបល់ ឬដោះស្រាយកិច្ចការមូលដ្ឋាននៅក្នុងភាពជាតំណាងផលប្រយោជន៍ផ្ទាល់របស់ប្រជាពលរដ្ឋ។ នាពេលកន្លងទៅ ក្រុមប្រឹក្សាឃុំ សង្កាត់បានរៀបចំកិច្ចប្រជុំសាមញ្ញបានទៀងទាត់ ព្រមទាំងបានរៀបចំកិច្ចប្រជុំវិសាមញ្ញទៅតាមការចាំបាច់។

ជាលទ្ធផល ក្រុមប្រឹក្សាឃុំ សង្កាត់នៅអាណត្តិទី៥ឆ្នាំ២០២២ ដល់ឆ្នាំ២០២៥ បានរៀបចំកិច្ចប្រជុំសាមញ្ញចំនួន៧៩.២៩៦កិច្ចប្រជុំ។ ក្រៅពីកិច្ចប្រជុំសាមញ្ញ ក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំវិសាមញ្ញដើម្បីធ្វើការដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋនិងឆ្លើយតបចំពោះតម្រូវការប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលាចំនួន៦៣.៧៨២កិច្ចប្រជុំ ដែលក្នុងកិច្ចប្រជុំមានលក្ខណៈសម្ងាត់ចំនួន១.៨៨៩កិច្ចប្រជុំ។

ក្រាហ្វ២.១៖ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាតាមឆ្នាំ




### ២.៥- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ និងគណៈ-កម្មការនានា

នៅតាមរដ្ឋបាលឃុំ សង្កាត់នីមួយៗគឺតម្រូវឱ្យមានគណៈកម្មាធិការជាកាតព្វកិច្ចចំនួន៣ គឺគណៈ-កម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) គណៈកម្មាធិការកសាងផែនការនិងថវិកា និងគណៈកម្មាធិការលទ្ធកម្ម។ ទន្ទឹមនេះ រដ្ឋបាលឃុំ សង្កាត់ក៏អាចបង្កើតគណៈកម្មាធិការផ្សេងៗជាជម្រើសស្របតាមតម្រូវការចាំបាច់នៅតាមឃុំ សង្កាត់របស់ខ្លួន។

គ.ក.ន.ក. គឺជាសេនាធិការដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីផ្តល់យោបល់ និងជួយលើកិច្ចការនារីនិងកុមារ ព្រមទាំងការងារសេវាសង្គមផ្សេងៗទៀត។ ផ្អែកតាមប្រកាសលេខ៣៨៤០ ប្រក. ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ និងសារាចរអន្តរក្រសួងរវាងក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ០០៧សហវ-ស.រ.អហក ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម

និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ គ.ក.ន.ក. បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន ដែលផ្តោតលើ ១១ វិស័យ ដូចមានរំលេចនៅក្នុង **ចំណុចទី ២.៧** ខាងក្រោម។ លើមូលដ្ឋាននេះ គ.ក.ន.ក បានសហការជាមួយបុស្តិ៍នគរបាលរដ្ឋបាល មណ្ឌលសុខភាព សាលារៀន មាតាបិតាសិស្ស សិស្សនៅសាលារៀន អង្គការមិនមែនរដ្ឋាភិបាល សមាគម ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការលើកកម្ពស់សុខុមាលភាព និងសុខភាពរបស់ស្ត្រី និងកុមារ និងជនងាយរងគ្រោះផ្សេងៗទៀត។

ជាមួយគ្នានេះ ដោយប្រទេសកម្ពុជា ជាប្រទេសមួយដែលមានចំណែកប្រជាជនវ័យក្មេងច្រើន ជាពិសេសយុវជន នេះបើផ្អែកតាមរបាយការណ៍របស់អង្គការសហប្រជាជាតិដើម្បីការអភិវឌ្ឍន៍ ហៅកាត់ថា UNDP ក្រសួងមហាផ្ទៃក៏បានដាក់ចេញនូវសេចក្តីណែនាំលេខ០៤៥ ស.ណ.ន. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការជ្រើសរើសតំណាងយុវជនចូលរួមជាសមាជិកគណៈកម្មាធិកាទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជននៅក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន រួមទាំងបង្កើតជាយន្តការអចិន្ត្រៃយ៍មួយនៅក្នុងការជំរុញឱ្យក្រុមប្រឹក្សាឃុំ សង្កាត់បង្កើននូវការយកចិត្តទុកដាក់លើបញ្ហាយុវជន ដែលជាកម្លាំងចលករ ដ៏សំខាន់នៅក្នុងការរួមចំណែកជំរុញសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា។

ដោយឡែកគណៈកម្មាធិការកសាងផែនការនិងថវិកា ក៏បានជួយដល់ក្រុមប្រឹក្សានៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់រយៈពេល ០៥ ឆ្នាំ ក្រោយពីក្រុមប្រឹក្សាអាណត្តិទី៥បានចូលកាន់តំណែង និងបានជួយរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ និងផែនការថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់រៀងរាល់ឆ្នាំ។ ចំណែកគណៈកម្មាធិការលទ្ធកម្មក៏បានជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តកិច្ចដំណើរការលទ្ធកម្មនានារបស់រដ្ឋបាលឃុំ សង្កាត់ស្របតាមគោលការណ៍និងនីតិវិធីដែលបានកំណត់ក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងឃុំ សង្កាត់។

## ២.៦- ការកសាងនិងការអនុវត្តផែនអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់រដ្ឋបាលឃុំ សង្កាត់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានតម្រូវឱ្យក្រុមប្រឹក្សានៃរដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវរៀបចំផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនានា។ ផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ គឺជាផែនទីបង្ហាញផ្លូវដ៏សំខាន់របស់រដ្ឋបាលឃុំ សង្កាត់ ដែលកំណត់អំពីទស្សនវិស័យ កម្មវិធី និងការអភិវឌ្ឍឃុំ សង្កាត់ ក្នុងរយៈពេល៥ឆ្នាំ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ ផែនការអភិវឌ្ឍន៍នេះត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ តាមរយៈកម្មវិធីវិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំ។

នៅក្នុងអាណត្តិទី៥នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗទូទាំងប្រទេសបានរៀបចំផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំបានទាន់ពេលវេលា។ ការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគនេះ ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់«គ.ផ.ថ.» ដែលជាគណៈកម្មការធិការមួយរបស់ក្រុមប្រឹក្សា ហើយត្រូវអនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ ឬកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់ចែកចេញ៤ផ្នែក គឺផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកធនធានធម្មជាតិ បរិស្ថាននិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផ្នែករដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់

សាធារណៈ។ ផែនការទាំងនេះត្រូវបានរៀបចំឡើងដោយពិគ្រោះយោបល់ថ្នាក់ភូមិ ឃុំ សង្កាត់ ដែលមានការចូលរួមពីប្រជាពលរដ្ឋដោយផ្ទាល់ និងតាមរយៈតំណាងរបស់ប្រជាជន ដើម្បីលើកឡើងនូវបញ្ហាឬតម្រូវការជាអាទិភាព។ ម្យ៉ាងវិញទៀត ដំណើរការនៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលបានផ្តល់ឱកាសដល់មន្ទីរ អង្គភាពជំនាញ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ធ្វើកិច្ចពិភាក្សាអំពីគម្រោងអភិវឌ្ឍនានាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងគាំទ្រដល់គម្រោងវិនិយោគនានារបស់ឃុំ សង្កាត់ ដែលធ្វើឡើងតាមរយៈសិក្ខា-សាលាសមាហរណកម្មនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

កន្លងមកនេះ ដើម្បីពង្រឹងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងមហាផ្ទៃបានដាក់ចេញនូវសេចក្តីណែនាំជាច្រើន ដើម្បីជំរុញដល់រដ្ឋបាលរាជធានី ខេត្តក្នុងការជួយគាំទ្រការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ ឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់ ឱ្យទាន់ពេលវេលា។ ជាមួយគ្នានេះ ក្រសួងមហាផ្ទៃ ដែលមានអគ្គនាយកដ្ឋានរដ្ឋបាលជាសេនាធិការ និងដោយមានការគាំទ្រពីអង្គការយូនីសេហ្វបានធ្វើការសិក្សាវាយតម្លៃលើដំណើរការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលឃុំ សង្កាត់ដែរ និងបានរៀបចំនូវរបាយការណ៍លទ្ធផលវាយតម្លៃក្នុងឆ្នាំ២០២៥ នេះ។ លទ្ធផលនៃការសិក្សាវាយតម្លៃនេះនឹងត្រូវបានប្រើប្រាស់សម្រាប់ពិនិត្យ និងកែលម្អផែនការអភិវឌ្ឍន៍របស់រដ្ឋបាលឃុំ សង្កាត់ នាពេលខាងមុខនេះផងដែរ។

## ២.៧- ថវិកាឃុំ សង្កាត់ ២០២២-២០២៦

### ២.៧.១ ប្រភពពីមូលនិធិឃុំ សង្កាត់

ចាប់តាំងពីការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់ រាជរដ្ឋាភិបាលបានបង្កើតមូលនិធិឃុំ សង្កាត់ ដែលជាប្រភពចំណូលថវិកាដ៏ចម្បងរបស់រដ្ឋបាលឃុំ សង្កាត់។ ជាដំបូង មូលនិធិនេះចែកចេញជាពីរសមាសភាគ គឺសមាសភាគរដ្ឋបាលទូទៅ និងសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។ សមាសភាគរដ្ឋបាលទូទៅនេះគឺសម្រាប់ការចំណាយលើប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា មន្ត្រីកិច្ចសន្យា និងមន្ត្រីភូមិ ខណៈដែលសមាសភាគផ្នែកអភិវឌ្ឍន៍មូលដ្ឋានគឺសម្រាប់ចំណាយលើការអភិវឌ្ឍមូលដ្ឋាន ដែលកន្លងមកនេះភាគច្រើនចំណាយលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសផ្លូវលំជនបទ។ ដោយឡែក ក្នុងអាណត្តិទី៥ នៃក្រុមប្រឹក្សាឃុំ សង្កាត់ និងដោយមើលឃើញនូវការកើនឡើងពីតម្រូវការសេវាសង្គម ការគាំពារសង្គម ព្រមទាំងការលើកកម្ពស់អនាម័យបរិស្ថាន និងការទប់ស្កាត់គ្រោះមហន្តរាយនានា ជាពិសេសដើម្បីរួមចំណែកស្តារឡើងវិញនូវផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ចេញនូវអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមូលនិធិថវិកាជូនមូលនិធិឃុំ សង្កាត់ ដោយធ្វើការបែងចែកមូលនិធិឃុំ សង្កាត់ ជាបីសមាសភាគ គឺសមាសភាគរដ្ឋបាលទូទៅ សមាសភាគសេវាសង្គមនិងអនាម័យបរិស្ថាន និងសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។

ផ្អែកតាមអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ខាងលើនេះ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានដាក់ចេញសារាចរអន្តរក្រសួងលេខ០០៧ ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ នាថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២៥ ដែលមុខសញ្ញាចំណាយសមាសភាគនេះ គឺផ្តោតទៅលើវិស័យសំខាន់ៗចំនួន១១ រួមមាន៖

១. ការលើកកម្ពស់សុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ
២. ការពង្រឹង និងពង្រីកការអប់រំកុមារតូច
៣. ការលើកកម្ពស់គុណភាពអប់រំបឋមសិក្សា និងមធ្យមសិក្សា
៤. កិច្ចការពារស្ត្រី និងកុមារ
៥. ការលើកកម្ពស់សមភាពយេនឌ័រ
៦. កិច្ចគាំទ្រ និងជំរុញការអនុវត្តកម្មវិធីគាំពារសង្គម
៧. ការពង្រឹងការយល់ដឹង និងទប់ស្កាត់ ការរីករាលដាលជំងឺឆ្លង និងជំងឺមិនឆ្លង
៨. ការលើកកម្ពស់គណនេយ្យភាពសង្គម
៩. ទឹកស្អាត និងអនាម័យ
១០. ការគ្រប់គ្រងសំណល់រឹង រាវ និង
១១. ការប្រែប្រួលអាកាសធាតុ។

ការដាក់ចេញនូវអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ខាងលើនេះ រួមទាំងការដាក់ចេញនូវសារាចរអន្តរក្រសួងលេខ០០៧ គឺពិតជាទទួលបានការសារទរ និងការគាំទ្រយ៉ាងច្រើនពីសំណាក់រដ្ឋបាលថ្នាក់ក្រោមជាតិ សាធារណជន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីរួមចំណែកនៅក្នុងការលើកកម្ពស់សុខមាលភាព និងសុខភាពរបស់ប្រជាពលរដ្ឋ ជាពិសេសជនងាយរងគ្រោះ ដែលមានស្ត្រី កុមារ ចាស់ជរា ជនក្រីក្រ ជនមានពិការភាព និងអ្នកងាយរងគ្រោះដ៏ទៃទៀត ដោយឈរលើគោលការណ៍មិនបោះបង់នរណាម្នាក់ចោលឡើយ។

នៅក្នុងអាណត្តិទី៥ នេះ មូលនិធិឃុំ សង្កាត់ត្រូវបានវិភាជន៍ក្នុងអត្រាជាមធ្យមប្រមាណ ៣,៤៤% នៃចំណូលចរន្តថ្នាក់ជាតិចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ និងកើនឡើងក្នុងអត្រាជាមធ្យម ១៣% ក្នុងមួយឆ្នាំ។ ទន្ទឹមនេះ ក្នុងអាណត្តិទី ៥ (២០២២-២០២៦) នេះ មូលនិធិឃុំ សង្កាត់មានទំហំថវិកាសរុបប្រមាណ **៤.៣៦៥.៩៤៦ (បួនលានបីរយហុកប្រាំពាន់ប្រាំបួនរយសែសិបប្រាំមួយ) លានរៀល** ស្មើនឹងប្រមាណ **១.០៧៨ លានដុល្លារសហរដ្ឋអាមេរិក** ច្រើនជាងជិត២ ដង នៃមូលនិធិឃុំ សង្កាត់ កាលពីអាណត្តិទី៤ (គិតពីឆ្នាំ២០១៧-២០២១) ដែលមានទំហំប្រមាណតែ **២.៤៨១.២៣៩ (ពីរលានបួនរយប៉ែតសិបមួយពាន់ពីររយសាមសិបប្រាំបួន) លានរៀល** ស្មើនឹងប្រមាណ**៦១៣ លាន ដុល្លារសហរដ្ឋអាមេរិក** តែប៉ុណ្ណោះ។

**តារាង២.៣ មូលនិធិឃុំ សង្កាត់ប្រចាំឆ្នាំ២០២២-២០២៦ (ឯកតាលានរៀល)**

| ឆ្នាំ | ផ្នែករដ្ឋបាល | ផ្នែកអភិវឌ្ឍន៍ | ផ្នែកសេវាសង្គមនិងអនាម័យបរិស្ថាន | មូលនិធិសរុប | កំណើន | អត្រាវិភាជន៍នៃចំណូលចរន្តថ្នាក់ជាតិ |
|---|---|---|---|---|---|---|
| 2022 | 452,721 | 236,288 | - | 689,009 | 27.45% | 3.30% |
| 2023 | 474,248 | 298,218 | - | 772,466 | 12.11% | 3.40% |
| 2024 | 529,444 | 325,277 | 65,055 | 919,776 | 19.07% | 3.50% |
| 2025 | 544,785 | 357,205 | 107,287 | 1,009,277 | 9.73% | 3.50% |
| 2026 | 537,391 | 314,481 | 123,546 | 975,418 | -3.35% | 3.50% |
| **សរុប** | **2,538,589** | **1,531,469** | **295,888** | **4,365,946** | | |

សម្គាល់៖ ១ ដុល្លារសហរដ្ឋអាមេរិកស្មើ ៤.០៥០ រៀល

### ២.៧.២ ប្រភពពីថវិកាផ្សេងៗទៀត

ក្រៅពីមូលនិធិឃុំ សង្កាត់ ដែលជាប្រភពថវិកាចម្បង និងក្នុងគោលបំណងបង្កើននូវការអភិវឌ្ឍមូលដ្ឋាន ដើម្បីរួមចំណែកដល់ការលើកកម្ពស់សេដ្ឋកិច្ច-សង្គមនៅមូលដ្ឋាន ឱ្យកាន់តែមានភាពល្អប្រសើរ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបន្ថែមថវិកាចំនួន១ភាគរយ នៃចំណូលចរន្តថ្នាក់ជាតិ និងពន្ធចែករំលែក ៦% ពីរដ្ឋបាលរាជធានី ខេត្ត ដល់រដ្ឋបាលឃុំ សង្កាត់ លើកលែងរដ្ឋបាលសង្កាត់ទាំង១០៥ នៅក្នុងរាជធានីភ្នំពេញ សម្រាប់គាំទ្រចំណាយលើការអភិវឌ្ឍមូលដ្ឋាន។

ជារួម ថវិកាដែលត្រូវបន្ថែមសម្រាប់មូលនិធិឃុំ សង្កាត់ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ សម្រាប់ផ្នែកអភិវឌ្ឍន៍តាមរយៈចំណូលចរន្តថ្នាក់ជាតិ ១% និងពន្ធចែករំលែកពីរដ្ឋបាលរាជធានីខេត្ត មានចំនួនសរុបចំនួន**១.៥៦០.៩៣១ (មួយលានប្រាំរយហុកសិបពាន់ប្រាំបួនរយសាមសិបមួយ) លានរៀល** ស្មើនឹងប្រមាណ **៣៨៥ លានដុល្លារសហរដ្ឋអាមេរិក** ក្នុងនោះទំហំថវិកាដែលរដ្ឋបាលឃុំ សង្កាត់ទទួលបានពីការបន្ថែមថវិកា១% មានចំនួនសរុប **១.២៤១.៣៣៥ (មួយលានពីររយសែសិបមួយពាន់បីរយសាមសិបប្រាំ) លានរៀល** ស្មើនឹងប្រមាណ **៣០៦ លានដុល្លារសហរដ្ឋអាមេរិក** និងពន្ធចែករំលែកសរុបចំនួន **៣១៩,៥៩៦ (បីរយដប់ប្រាំបួនប្រាំរយកៅសិបប្រាំមួយ) លានរៀល** ស្មើនឹងប្រមាណ **៧៩ លានដុល្លារសហរដ្ឋអាមេរិក។**

**តារាង២.៤ ប្រភពថវិកាផ្សេងៗ របស់រដ្ឋបាលឃុំ សង្កាត់ ប្រចាំឆ្នាំ២០២២-២០២៦ (ឯកតាលានរៀល)**

| ឆ្នាំ | ១% នៃចំណូលចរន្តថ្នាក់ជាតិ | ពន្ធចែករំលែក ពីរាជធានី ខេត្ត | សរុប |
|---|---|---|---|
| 2022 | 197,059 | 44,776 | 241,835 |
| 2023 | 221,573 | 71,630 | 293,203 |
| 2024 | 255,644 | 109,318 | 364,962 |
| 2025 | 288,365 | 0 | 288,365 |
| 2026 | 278,694 | 93,872 | 372,566 |
| **សរុប** | **1,241,335** | **319,596** | **1,560,931** |

សម្គាល់៖ ១ ដុល្លារសហរដ្ឋអាមេរិកស្មើ ៤.០៥០ រៀល

### ២.៧.៣ ថវិកាសរុបឃុំ សង្កាត់

ផ្អែកតាមចំណុច **២.៧.១** និង**២.៧.២** ខាងលើនេះ នៅក្នុងអាណត្តិទី៥ ដោយគិតចាប់តាំងពីឆ្នាំ ២០២២ដល់២០២៦នេះ ថវិកាសរុបរបស់រដ្ឋបាលឃុំ សង្កាត់មានចំនួន **៥.៩២៦.៨៧៧ (ប្រាំលានប្រាំបួនរយម្ភៃប្រាំមួយពាន់ប្រាំបីរយចិតសិបប្រាំពីរ)** លានរៀល ស្មើនឹង **១.៤៦៣ លានដុល្លារសហរដ្ឋអាមេរិក** និងមានកំណើនក្នុងអត្រា ១០% ក្នុងមួយឆ្នាំ។

ដោយឡែក ក្នុងឆ្នាំ២០២២ នេះ ថវិកាឃុំ សង្កាត់មានទំហំប្រមាណ **៩៣០.៨៤៤ (ប្រាំបីរយពាន់ប្រាំបីរយសែសិបបួន) លានរៀល** ស្មើនឹងប្រមាណ **២៣០ ដុល្លារសហរដ្ឋអាមេរិក** និងកើនឡើងដល់ **១.៣៤៧.៩៨៤ (មួយលានបីរយសែសិបប្រាំពីរពាន់ប្រាំបួនរយប៉ែតសិប៤) លានរៀល** ស្មើនឹងប្រមាណ **៣៣៣ លានដុល្លារសហរដ្ឋអាមេរិក** ក្នុងឆ្នាំ២០២៦។ រហូតមកដល់ឆ្នាំ ២០២៦ ឃុំ សង្កាត់នីមួយៗមាន

ថវិកាជាមធ្យប្រមាណ **៨៣២ លានរៀល**ក្នុងមួយឆ្នាំ ស្មើនឹងប្រមាណ **២០៥.៤៣២ (ពីររយប្រាំពាន់បួនរយសាមសិបពីរ) ដុល្លារសហរដ្ឋអាមេរិក**។ បើធៀបនឹងការចាប់ផ្តើមដំបូងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ កាលពីឆ្នាំ២០០២ ឃុំ សង្កាត់នីមួយៗមានថវិកាជាមធ្យមមានប្រមាណ **៧.៨៣២ ដុល្លារសហរដ្ឋអាមេរិក** និងកើនដល់ប្រមាណជិត ៨០.០០០ **ដុល្លារសហរដ្ឋអាមេរិក** ក្នុងឆ្នាំ២០១៩ ប៉ុណ្ណោះ។

**តារាង២.៥ ថវិកាសរុបរបស់រដ្ឋបាលឃុំ សង្កាត់ ប្រចាំឆ្នាំ២០២២-២០២៦ (ឯកតាលានរៀល)**

| ឆ្នាំ | មូលនិធិឃុំ សង្កាត់ | ១% នៃចំណូលចរន្តថ្នាក់ជាតិ | ពន្ធចែករំលែកពីរាជធានី ខេត្ត | សរុប | %កំណើន | ថវិកាជាមធ្យម/ឃុំ សង្កាត់ |
|---|---|---|---|---|---|---|
| 2022 | 689,009 | 197,059 | 44,776 | 930,844 | | 576 |
| 2023 | 772,466 | 221,573 | 71,630 | 1,065,669 | 14% | 659 |
| 2024 | 919,776 | 255,644 | 109,318 | 1,284,738 | 21% | 794 |
| 2025 | 1,009,277 | 288,365 | 0 | 1,297,642 | 1% | 869 |
| 2026 | 975,418 | 278,694 | 93,872 | 1,347,984 | 4% | 832 |
| **សរុប** | **4,365,946** | **1,241,335** | **319,596** | **5,926,877** | | |

**សម្គាល់៖** ១ ដុល្លារសហរដ្ឋអាមេរិកស្មើ ៤.០៥០ រៀល

ម្យ៉ាងវិញទៀត នៅក្នុងអាណត្តិទី៥នេះ ប្រសិនបើយើងធ្វើបែងចែកចំណែកថវិកាឃុំ សង្កាត់ តាមសមាសភាគទាំងបី គឺសមាសភាគរដ្ឋបាល សមាសភាគសេវាសង្គមនិងអនាម័យបរិស្ថាន និងសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន (សរុបទាំងថវិកាបន្ថែម១% នៃចំណូលចរន្តថ្នាក់ជាតិ និងពន្ធចែករំលែករាជធានី ខេត្ត) នោះយើងឃើញថាចំណែកថវិកាសម្រាប់ការចំណាយលើសមាសភាគផ្នែកអភិវឌ្ឍន៍មានទំហំ ៥២ ភាគរយ និងចំណាយសម្រាប់សមាសភាគរដ្ឋបាលមានទំហំ ៤៣% និងសមាសភាគសេវាសង្គមនិងអនាម័យបរិស្ថានមានទំហំត្រឹម ៥%។ ទិន្នន័យនេះបង្ហាញថា រដ្ឋបាលឃុំ សង្កាត់ចំណាយច្រើនលើផ្នែកអភិវឌ្ឍន៍មូលដ្ឋាន ហើយដែលភាគច្រើនជាការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅមូលដ្ឋាន។

ក្រាហ្វ២.២៖ ភាគរយនៃចំណែកចំណាយសមាសភាគទាំង៣ ២០២២-២០២៦



ជារួម ការកើនឡើងនូវថវិកាឃុំ សង្កាត់ ពីមួយអណត្តិទៅមួយអាណត្តិនេះគឺជាការបង្ហាញពីការយកចិត្តទុកដាក់ និងផ្តល់អាទិភាពដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ របស់រាជរដ្ឋាភិបាល ក្នុងគោលបំណង ដើម្បីបន្តការលើកកម្ពស់ប្រជាធិបតេយ្យនៅមូលដ្ឋាន និងរួមចំណែកកាត់បន្ថយនូវភាពក្រីក្រ ព្រមទាំងដើម្បីសម្រេចនូវចក្ខុវិស័យនៅឆ្នាំ ២០៥០ របស់រាជរដ្ឋាភិបាលផងដែរ។

## ២.៨-ការអនុវត្តគម្រោងរបស់រដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមផែនការអភិវឌ្ឍឃុំ សង្កាត់៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់បានរៀបចំជាគម្រោងអភិវឌ្ឍន៍ ដើម្បីអនុវត្តប្រចាំឆ្នាំ។ គម្រោងនេះមាន៤ផ្នែក គឺផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផ្នែករដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ។ ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់នេះ ត្រូវបានធ្វើឡើងស្របតាមសេចក្តីសម្រេចលេខ ០៩៧ ស.ស.រ./គ.ជ.អ.ប. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការ អនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។ សៀវភៅណែនាំខាងលើនេះ គឺជានីតិវិធីប្រតិបត្តិស្តង់ដា នៅក្នុងការអនុវត្តគម្រោងឃុំ សង្កាត់ ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព ការចូលរួម និងបរិយាបន្ន។

ក្នុងអាណត្តិទី៥នៃក្រុមប្រឹក្សាឃុំ សង្កាត់ គិតចាប់ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៥ គម្រោងផ្នែកសេដ្ឋកិច្ចបានអនុវត្តបញ្ចប់មានចំនួនសរុប ៩.៨២៤ គម្រោង ដែលគម្រោងទាំងនោះរួមមាន៖ ការស្ថាបនាផ្លូវលំជនបទ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងការជម្រុញផលិតកម្មកសិកម្ម ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ដោយឡែកនៅក្នុងអាណត្តិទី៥ នេះផងដែរ ចំនួនគម្រោងផ្នែកសង្គមកិច្ចដែលបានអនុវត្តបញ្ចប់មានចំនួនសរុប ៣៤.៦៣០ គម្រោងឬសកម្មភាព ដែលគម្រោងឬសកម្មភាពទាំងនោះ ផ្តោតលើ៖ មត្តេយ្យសហគមន៍ ការលើកកម្ពស់សុខុមាលភាពសាធារណៈ ការគាំពារសង្គម ការការពារជនងាយរងគ្រោះនានា ការផ្សព្វផ្សាយសុខភាព អនាម័យ ការប្រើប្រាស់ទឹកស្អាត អនាម័យសុខភាពបន្តពូជ អំពើហឹង្សាក្នុងគ្រួសារ ការលើកកម្ពស់យេនឌ័រ ការផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃសំបុត្រអត្រានុកូលដ្ឋាន ព្រមទាំងការងារគណនេយ្យភាពសង្គមជាដើម ដើម្បីលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់។

ទន្ទឹមនេះ នៅក្នុងអាណត្តិទី៥ រដ្ឋបាលឃុំ សង្កាត់ ក៏បានអនុវត្តបញ្ចប់គម្រោងផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ចំនួនសរុប ៧.៥៨៥ គម្រោងឬសកម្មភាព ដែលគម្រោងឬសកម្មភាពទាំងនេះ រួមមាន៖ ការគ្រប់គ្រងសំណល់ ការដាំដើមឈើ ការផ្សព្វផ្សាយស្តីពីច្បាប់ភូមិបាល ការចុះសម្អាតបរិស្ថានតាមដងផ្លូវនៅក្នុងឃុំ សង្កាត់ សេវាប្រមូលសំរាមតាមផ្ទះ ការចុះដាំដើមឈើតាមភូមិដងផ្លូវ ការដាំកូនឈើក្នុងព្រៃសហគមន៍និងតំបន់អភិរក្ស និងការចុះជួយប្រជាពលរដ្ឋនៅពេលជួបគ្រោះមហន្តរាយនានា ដោយសារបាតុភូតធម្មជាតិ។

បន្ថែមលើសពីនេះ ក្នុងអាណត្តិទី៥ នេះដែរ រដ្ឋបាលឃុំ សង្កាត់ក៏បានអនុវត្តបញ្ចប់គម្រោងឬសកម្មភាព រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ សរុបចំនួន ១២.៥២២ គម្រោងឬសកម្មភាព ដែលគម្រោង

ឬសកម្មភាពទាំងនោះ រួមមាន៖ ការសហការជាមួយស្ត្រីរដ្ឋបាល អាជ្ញាធរភូមិ និងប្រជាការពារចុះផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពនៅតាមភូមិ ការចុះល្បាតនៅពេលយប់ ការចុះត្រួតពិនិត្យអាវុធជាតិផ្ទុះ ចុះការពារតាមកម្មវិធីបុណ្យការផ្សេងៗ ការចុះសម្រួលចរាចរណ៍តាមផ្លូវ និងតាមសាលារៀន និងសកម្មភាពផ្សេងៗទៀត ដើម្បីលើកកម្ពស់សណ្តាប់ និងសន្តិសុខសាធារណៈ ព្រមទាំងកាត់បន្ថយនូវបទល្មើសផ្សេងៗក្នុងមូលដ្ឋាន។

**តារាង២.៦ ចំនួនគម្រោងដែលបានអនុវត្តបញ្ចប់ ដោយរដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ២០២២ ដល់២០២៥**

| ល.រ | ប្រភេទគម្រោង | ចំនួនគម្រោងឬសកម្មភាពបានអនុវត្តបញ្ចប់ | | | | សរុប |
|---|---|---|---|---|---|---|
| | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | |
| ១ | ផ្នែកសេដ្ឋកិច្ច | 2,288 | 2,447 | 2,492 | 2,597 | 9,824 |
| ២ | ផ្នែកសង្គមកិច្ច | 6,740 | 7,743 | 9,179 | 10,968 | 34,630 |
| ៣ | ផ្នែកធនធានធម្មជាតិបរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | 1,325 | 1,642 | 1,872 | 2,746 | 7,585 |
| ៤ | ផ្នែករដ្ឋបាល និង សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | 2,624 | 2,751 | 3,325 | 3,822 | 12,522 |



គម្រោងស្ថាបនាផ្លូវបេតុង ក្នុងសង្កាត់អូរចារ ក្រុងបាត់ដំបង ខេត្តបាត់ដំបង



សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់



សកម្មភាព សេវាសង្គម ក្នុងសង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប



ផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

បើទោះជា គម្រោងឬសកម្មភាព ក្រៅពីគម្រោងឬសកម្មភាពសេដ្ឋកិច្ច មានចំនួនច្រើនក៏ដោយ តែថវិកាឃុំ សង្កាត់ ក្នុងអាណត្តិទី៥នេះ នៅតែចំណាយភាគច្រើនលើគម្រោងផ្នែកសេដ្ឋកិច្ច ដោយសារគម្រោងផ្នែកសេដ្ឋកិច្ចនេះផ្តោតលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសគម្រោងផ្លូវលំជនបទ ដែលរួមមានផ្លូវបេតុង ផ្លូវកៅស៊ូ ផ្លូវគ្រួសក្រហម ការសាងស្ពានបេតុង និងផ្លូវផ្សេងៗទៀត ដែលត្រូវការចំណាយថវិកាច្រើន។ ក្នុងអាណត្តិទី៥ នេះ រដ្ឋបាលឃុំ សង្កាត់ ក៏បានសាងសង់ផ្លូវបេតុងក្នុងប្រវែងសរុបចំនួន ៤.៥២០,៨២ គីឡូម៉ែត ផ្លូវកៅស៊ូចំនួន ៤០,២៣ គីឡូម៉ែត ផ្លូវគ្រួសក្រហមចំនួន ១១.៤៣៤,១៨ គីឡូម៉ែត ស្ពានបេតុង ២៩,១០ គីឡូម៉ែត និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ដើម្បីសម្រួលដល់ការតភ្ជាប់ពីមូលដ្ឋានទៅតំបន់ទីប្រជុំជននានា និងសម្រួលដល់ការដឹកជញ្ជូនកសិផល និងទំនិញនានារបស់ប្រជាពលរដ្ឋទៅកាន់ទីផ្សារ ដែលនឹងរួមចំណែកដល់ការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ។

**តារាង២.៧ ប្រវែងផ្លូវលំជនបទ និងសំណង់ផ្សេងៗពីឆ្នាំ២០២២ ដល់២០២៥**

| បរិយាយ | ហេដ្ឋារចនាសម្ព័ន្ធតាមឆ្នាំ(គិតជាគីឡូម៉ែត្រ) | | | | សរុប |
|---|---|---|---|---|---|
| | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | |
| ផ្លូវបេតុង | 1,020.30 | 1,112.19 | 1,592.20 | 1220.674 | 4,945.37 |
| ផ្លូវកៅស៊ូ | 14.37 | 14.21 | 4.01 | 7.63 | 40.23 |
| ផ្លូវគ្រួសក្រហម | 2,916.45 | 3,018.59 | 3,361.96 | 2137.18 | 11,434.18 |
| ផ្លូវដីគ្រួសធម្មជាតិ | 1,049.27 | 1,055.00 | 958.34 | 894.96 | 3,957.57 |
| ផ្លូវក្រាលកំទេចថ្មមិច | 8.86 | 4.85 | 5.20 | 1.7 | 20.60 |
| ផ្លូវក្រាលថ្មបំបែក | 191.89 | 238.31 | 238.62 | 292.43 | 961.25 |
| ផ្លូវក្រាលខ្សាច់ភ្នំ | 532.35 | 469.47 | 437.59 | 588.69 | 2,028.10 |
| ផ្លូវដីស | 39.15 | 58.23 | 80.59 | 62.37 | 240.34 |
| ការសាងសង់ស្ពានបេតុង | 2.09 | 8.00 | 8.00 | 11.01 | 29.10 |
| ផ្លូវផ្សេងៗ.... | 34.44 | 17.41 | 20.13 | 14.80 | 86.79 |
| ធ្វើលូរំដោះទឹក | 131.49 | 111.82 | 102.81 | 94.64 | 440.76 |
| ស្ពានប្រឡាយ | 153.38 | 158.70 | 92.70 | 155.90 | 560.69 |

ជារួម លទ្ធផលដែលទទួលបានពីការអនុវត្តគម្រោងខាងលើនេះ ពិតជាបានរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅមូលដ្ឋាន សំដៅរួមចំណែកការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងកាត់បន្ថយនូវភាពក្រីក្រ ព្រមទាំងដើម្បីរួមចំណែកសម្រេចបាននូវចក្ខុវិស័យឆ្នាំ ២០៥០ តាមរយៈការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គម្រោងសេវាសង្គម ការលើកកម្ពស់អនាម័យបរិស្ថាន ការបន្សាំនិងការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់សណ្តាប់ធ្នាប់សារធារណៈ ។

## ២.៩-ស្ថានភាពអគាររដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ត្រូវមានសាលាឃុំ សង្កាត់ជាកន្លែងបំពេញការងាររបស់ក្រុមប្រឹក្សានិងបុគ្គលិករបស់ឃុំ សង្កាត់ និងកន្លែងផ្តល់សេវានានាជូនប្រជាជន។ ចាប់តាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០០២ដល់ឆ្នាំ២០២៥នេះ រដ្ឋបាលឃុំ សង្កាត់ភាគច្រើនទទួលបានអគាររដ្ឋបាលឃុំ សង្កាត់តាមគំរូស្តង់ដារ រដ្ឋបាលឃុំ សង្កាត់ខ្លះពុំទាន់មានអគាររដ្ឋបាលតាមគំរូស្តង់ដារ រដ្ឋបាលឃុំ សង្កាត់ខ្លះមានស្ថានភាពទ្រុឌទ្រោម និងឃុំ សង្កាត់គ្មានអគារនិងជួលអគារ ដើម្បីបំពេញការងារ។ ស្ថានភាពអគាររដ្ឋបាលឃុំ សង្កាត់ ទូទាំងប្រទេសមានស្ថានភាពដូចខាងក្រោម៖

ក)- រដ្ឋបាលឃុំ សង្កាត់ដែលមានអគាររដ្ឋបាលតាមគំរូស្តង់ដា ចំនួន១.៥២០ឃុំ សង្កាត់។

ខ)- រដ្ឋបាលឃុំ សង្កាត់ដែលមានអគាររដ្ឋបាលមិនតាមគំរូស្តង់ដា ចំនួន១៥៣ ឃុំ សង្កាត់។

គ)- រដ្ឋបាលឃុំ សង្កាត់ដែលមានអគាររដ្ឋបាលទ្រុឌទ្រោម ចំនួន៩៨ ឃុំ សង្កាត់។

ឃ)- រដ្ឋបាលឃុំ សង្កាត់ដែលគ្មានអគារឬជួលអគាររដ្ឋបាល ចំនួន១០ ឃុំ សង្កាត់។

ជាមួយគ្នានេះ ក្នុងអាណត្តិទី៥ នេះដែរ ដើម្បីរួមចំណែកដល់ការលើកកម្ពស់អនាម័យ និងបរិស្ថាន និងសោភណ្ឌភាពនៅតាមសាលាឃុំ សង្កាត់ ក្រសួងមហាផ្ទៃ ដោយមានការគាំទ្របច្ចេកទេស និងថវិកាពីអង្គការភ្លែនអន្តរជាតិបានដាក់ចេញនូវប្លង់បង្គន់អនាម័យស្តង់ដារ ប្រកបដោយបរិយាបន្ននៅតាមសាលាឃុំ សង្កាត់ កាលពីខែកក្កដា ឆ្នាំ២០២៥នេះ ដើម្បីសម្រួលដល់ប្រជាពលរដ្ឋ ចាស់ជរា ស្ត្រីមានផ្ទៃពោះ កុមារ ជនមានពិការភាព ដែលមកស្នើសុំ និងទទួលសេវានៅរដ្ឋបាលឃុំ សង្កាត់។ រហូតមកដល់ពេលនេះ មានឃុំ សង្កាត់ចំនួន ៦ ដែលបានសាងសង់បង្គន់អនាម័យឃុំ សង្កាត់នៅតាមសាលាឃុំ សង្កាត់របស់ខ្លួន។



ប្លង់បង្គន់អនាម័យគំរូស្តង់ដា ប្រកបដោយបរិយាបន្ននៅតាមសាលាឃុំ សង្កាត់

## ២.១០-ការងារបង្កើតភូមិ និងថ្នាក់ដឹកនាំភូមិ




ភូមិមិនមែនជាថ្នាក់រដ្ឋបាលដែលកំណត់ឡើងដោយរដ្ឋធម្មនុញ្ញនិងច្បាប់ឡើយ។ ភូមិមួយចំនួនរួមផ្តុំគ្នាបង្កើតបានជាឃុំ សង្កាត់ហើយភូមិមួយត្រូវមានប្រជាជនរស់នៅចាប់១៥០គ្រួសារឡើង។រដ្ឋបាលឃុំ សង្កាត់អាចស្នើសុំបង្កើតភូមិ ឬបង្រួមភូមិឬរំសាយភូមិស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃលេខ០០៤ ស.ណ.ន. ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ ស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ។ គិតមកដល់បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាមានភូមិសរុបចំនួន**១៤.៥៩០ភូមិ** ហើយភូមិនីមួយៗត្រូវមានលេខកូដសម្គាល់ដែលងាយស្រួលក្នុងការគ្រប់គ្រងទិន្នន័យផ្សេងៗឱ្យមានសង្គតិភាពទូទាំងប្រទេស ស្របតាមស្មារតីនៃអនុក្រឹត្យលេខ២៨០អនក្រ.បក. ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍និងបទប្បញ្ញត្តិនៃការកំណត់លេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជាណាចក្រកម្ពុជា។

ទោះបី ភូមិពុំមែនជាថ្នាក់រដ្ឋបាលដែលកំណត់ដោយច្បាប់ ភូមិនីមួយៗជាមូលដ្ឋានផ្ទាល់ក្នុងការរួមចំណែកអភិវឌ្ឍ ថែរក្សានិងការពារសន្តិសុខ និងសណ្តាប់សាធារណៈរបស់ឃុំ សង្កាត់ ព្រមទាំងជាខ្សែទំនាក់ទំនងរវាងភូមិនិងរដ្ឋបាលឃុំ សង្កាត់។ ភូមិនីមួយៗមានថ្នាក់ដឹកនាំបីរូប( ១រូបជាស្ត្រី )រួមមានមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ បានជ្រើសរើសនិងតែងតាំង ស្របតាមសេចក្តីណែនាំលេខ០០៤ ស.ណ.ន. ខាងលើ។ គិតមកដល់បច្ចុប្បន្ននេះ មន្ត្រីភូមិមានចំនួនសរុប ៤៣.៧៧០រូប ស្រី១២.៥២៨នាក់ (២៩%)។ ក្នុងការអនុវត្តតួនាទីជាមន្ត្រីភូមិនេះ មេភូមិទទួលបានប្រាក់ឧបត្ថម្ភចំនួន **៥៧០. ០០០រៀល** អនុប្រធានភូមិទទួលបានចំនួន **៤៤៥.០០០**រៀល ហើយសមាជិកភូមិទទួលបានចំនួន **៤១៥.០០០រៀល**។ មន្ត្រីភូមិទាំងនេះគឺជាកម្លាំងប្រតិបត្តិករជួរមុខដ៏សំខាន់ក្នុងការប្រមូល និងធ្វើបច្ចុប្បន្នភាពទិន្នន័យប្រជាសាស្ត្រ ការផ្សព្វផ្សាយគោលនយោបាយ ការប្រមូលព័ត៌មានតម្រូវការសម្រាប់ផែនការអភិវឌ្ឍន៍ ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ព្រមទាំងការឆ្លើយតបចំពោះគ្រោះមហន្តរាយ និងបញ្ហាបន្ទាន់នានាក្នុងសហគមន៍។

បច្ចុប្បន្នក្រសួងមហាផ្ទៃ ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ កំពុងតែសិក្សា និងវាយតម្លៃលើតួនាទីភារកិច្ចរបស់មន្ត្រីភូមិឡើងវិញ ដែលតួនាទីបច្ចុប្បន្ននេះត្រូវបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០០៦។ តាមរយៈគោលនយោបាយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មុខងារនិងធនធានរបស់រដ្ឋបាលថ្នាក់ជាតិ

ត្រូវបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិជាបន្តបន្ទាប់ ដែលចុងក្រោយគឺត្រូវមានការចូលរួមអនុវត្តពីមន្ត្រីភូមិផ្ទាល់តែម្តង ដែលធ្វើឱ្យមន្ត្រីមានភារកិច្ចកាន់តែច្រើនបន្ថែមទៀត។

តាមរយៈការវាយតម្លៃនេះ ក្រសួងមហាផ្ទៃក៏បានធ្វើនូវជំរឿនមន្ត្រីភូមិទូទាំងប្រទេសផងដែរ និងទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- មន្ត្រីភូមិចំនួនប្រមាណ ៤៨% នៃមន្ត្រីភូមិសរុបមានអាយុលើស៦០ ឆ្នាំ
- មេភូមិគ្របដណ្តប់ដោយបុរស ដោយមេភូមិជាស្ត្រីមានចំនួនត្រឹម ៨% នៃមេភូមិសរុប
- ៥៨% នៃមន្ត្រីភូមិទូទាំងប្រទេសបានដើរតួនាទីជាក្រុមទ្រទ្រង់សុខភាពភូមិ ដែលនេះក៏អាចជាហេតុផលមួយក្នុងចំណោមហេតុផលដ៏ទៃទៀត ដែលធ្វើឱ្យកម្ពុជាអាចទប់ស្កាត់នូវការរីករាលដាលនូវជំងឺឆ្លងផ្សេងបានទាន់ពេលវេលា រួមទាំងជំងឺកូវីដ-១៩
- ប្រមាណ៥០% នៃមន្ត្រីភូមិមានកម្រិតអប់រំត្រឹមបឋមសិក្សា ខណៈដែល៣៤% បានបញ្ចប់ការសិក្សាត្រឹមអនុវិទ្យាល័យ ព្រមទាំងប្រមាណ ១២% បានបញ្ចប់ការត្រឹមវិទ្យាល័យ និងមានចំនួនបន្តិចបន្តួចប៉ុណ្ណោះដែលបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា
- មន្ត្រីភូមិក៏មានសំណូមពរផងដែរនៅក្នុងការតម្លើងប្រាក់ឧបត្ថម្ភដល់ពួកគាត់ និងគិតគូរដល់ការចូលនិវត្តន៍របស់មន្ត្រីភូមិ ដោយពិចារណាក្នុងការផ្តល់ប្រាក់សោធននិវត្តន៍ និងការគាំទ្ររបបថែទាំសុខភាព

តាមរយៈលទ្ធផល ដែលទទួលបានពីជំរឿនខាងលើនេះ ក្រសួងមហាផ្ទៃនឹងសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីរួមចំណែកនៅក្នុងការបន្តលើកកម្ពស់ប្រសិទ្ធភាព នៃការអនុវត្តតួនាទី ភារកិច្ចមន្ត្រីភូមិ ឱ្យកាន់តែមានភាពល្អប្រសើរ។

បន្ថែមលើសពីនេះ នៅក្នុងអាណត្តិទី៥ នេះ មានភូមិចំនួន **១៧២** ត្រូវបានបង្កើតឡើងនៅក្នុងខេត្តចំនួន ១១ ដែលរួមមាន៖ ខេត្តកំពង់ចាម ក្រចេះ កំពត កំពង់ស្ពឺ ត្បូងឃ្មុំ បន្ទាយមានជ័យ បាត់ដំបង ពោធិ-សាត់ ព្រៃវែង ស្ទឹងត្រែង និងខេត្តឧត្តរមានជ័យ។

## ២.១១-ការងារផ្តល់សេវាសាធារណៈ

### ២.១១.១ ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ

ដូចបានរំលេចខាងលើ រដ្ឋបាលឃុំ សង្កាត់មានតួនាទីនិងភារកិច្ចបម្រើសេវាសាធារណៈសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចឃុំ សង្កាត់លើការរៀបចំនិងការចាត់ចែងសេវាសាធារណៈចាំបាច់សំខាន់ៗ និងបម្រើជាភ្នាក់ងារតំណាងរដ្ឋដែលបានកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ នៅក្នុងអាណត្តិទី៥ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ បានខិតខំផ្តល់សេវារដ្ឋបាលដល់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត ប្រកបដោយតម្លាភាព គណនេយ្យភាព និងរហ័សតាមយន្តការច្រកចេញចូលតែមួយ ស្របតាមអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្របតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃលេខ០១៨ ស.ណ.ន. ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់សេវាតាមយន្តការច្រកចេញចូលតែនៃរដ្ឋបាលឃុំ សង្កាត់ព្រមទាំងប្រកាសអន្តរ-

ក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ១៤៣៤២ ប្រក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងសម្រេចបាននូវសមិទ្ធផលដូចខាងក្រោម៖

**ក-អត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម**

រដ្ឋបាលឃុំ សង្កាត់ដែលមានមេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋានបានខិតខំរៀបចំ ចាត់ចែងក្នុងការផ្តល់សេវាអត្រានុកូលដ្ឋានទាំង១០ប្រភេទ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ១៤៣៤២ ប្រក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ និងបានខិតខំប្រឹងប្រែងជំរុញដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងការផ្តល់សេវា និងសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងអត្តសញ្ញាណបណ្ណជូនដល់ប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា។

ក្នុងរយៈពេលចាប់ឆ្នាំ២០២២ដល់ឆ្នាំ២០២៥ រដ្ឋបាលឃុំ សង្កាត់បានផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម រួមមាន៖

- បានចេញសំបុត្រអត្រានុកូលដ្ឋាន សំបុត្របញ្ជាក់អត្រានុកូលដ្ឋាន និងសេចក្តីចម្លងសំបុត្រអត្រា-នុកូលដ្ឋាន សរុបចំនួន ៨.៥៨៧.១៥៦សេវា។ បើគិតជាមធ្យម រដ្ឋបាលឃុំ សង្កាត់នីមួយៗបានផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការសំបុត្រអត្រានុកូលដ្ឋាន ចំនួន១.២៩៩ សេវាអត្រានុកូលដ្ឋានក្នុងរយៈពេល១ឆ្នាំ។
- បានផ្តល់សេវាអត្តសញ្ញាណកម្មសំខាន់ៗ ដែលរួមមាន៖ ជាសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងអត្តសញ្ញាណបណ្ណ សរុបចំនួន ៥.១៨២.០៤២សេវា។

**តារាង២.៨ សេវាអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម**

| ល.រ. | បរិយាយ | ចំនួនសេវាតាមឆ្នាំ | | | | សរុប |
|---|---|---|---|---|---|---|
| | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | |
| **អត្រានុកូលដ្ឋាន** | | **1,686,478** | **1,787,564** | **3,056,299** | **2,056,784** | **8,587,126** |
| ១ | សំបុត្រកំណើត | 237,498 | 240,561 | 246,603 | 368,408 | 1,093,071 |
| ២ | សំបុត្របញ្ជាក់កំណើត | 280,527 | 252,823 | 258,356 | 55,326 | 847,032 |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | 505,335 | 545,780 | 615,643 | 582,095 | 2,248,853 |
| ៤ | ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | 144,293 | 163,648 | 656,070 | 231,877 | 1,195,888 |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍(ខ្មែរ និងខ្មែរ) | 139,808 | 157,960 | 646,725 | 226,046 | 1,170,539 |
| ៦ | សំបុត្រអាពាហ៍ពិពាហ៍(ខ្មែរ និងបរទេស) | 4,485 | 5,688 | 9,345 | 5,831 | 25,349 |
| ៧ | សេចក្តីចម្លងសំបុត្រពាហ៍ពិពាហ៍(ខ្មែរនិងខ្មែរ) | 192,390 | 217,295 | 404,483 | 337,215 | 1,151,383 |
| ៨ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍(ខ្មែរនិងបរទេស) | 3,625 | 17,791 | 6,970 | 6,747 | 35,133 |

| ល.រ. | បរិយាយ | ចំនួនសេវាតាមឆ្នាំ | | | | សរុប |
|---|---|---|---|---|---|---|
| | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | |
| ៩ | សំបុត្រមរណភាព | 65,550 | 67,755 | 73,223 | 81,315 | 287,843 |
| ១០ | សេចក្ដីចម្លងសំបុត្រមរណភាព | 112,967 | 118,263 | 138,881 | 161,924 | 532,035 |
| **អត្តសញ្ញាណកម្ម(ករណីមានការផ្តល់សេវាពីរដ្ឋបាលឃុំ សង្កាត់)** | | **888,301** | **1,250,332** | **1,217,877** | **1,805,532** | **5,182,042** |
| ១ | សៀវភៅស្នាក់នៅ(ក២) | 182,124 | 218,473 | 197,122 | 217,328 | 835,047 |
| ២ | សៀវភៅគ្រួសារ(ក៤) | 138,845 | 183,745 | 147,201 | 202,154 | 671,945 |
| ៣ | អត្តសញ្ញាណបណ្ណ | 567,332 | 848,114 | 873,554 | 1,386,050 | 3,675,050 |

ខ- លិខិតបញ្ជាក់ផ្សេងៗ

ក្រៅពីការចេញលិខិតសំបុត្រអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម រដ្ឋបាលឃុំ សង្កាត់ក៏បានចេញនូវលិខិតបញ្ជាក់ផ្សេងៗដូចជា៖ លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ លិខិតបញ្ជាក់ទីលំនៅ លិខិតបញ្ជាក់តបណ្ដាញអគ្គសនី លិខិតបញ្ជាក់ផ្សេងៗទៀត រួមទាំងលិខិតបញ្ជាក់មួយចំនួនទៀតដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ។

ក្នុងរយៈពេលចាប់ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៥ សេវាលិខិតបញ្ជាក់ផ្សេងៗ ដែលបានចេញដោយរដ្ឋបាលឃុំ សង្កាត់ជូនដល់ប្រជាជន សរុបចំនួន ៩.០៥០.៨៧២ សេវា។ បើគិតជាមធ្យម រដ្ឋបាលឃុំ សង្កាត់នីមួយៗបានផ្តល់សេវាប្រមាណ១.៣៧០សេវា ក្នុងឆ្នាំ។

**តារាង២.៩ ប្រភេទលិខិតបញ្ជាក់ដែលចេញដោយរដ្ឋបាលឃុំ សង្កាត់**

| ល.រ. | បរិយាយ | ចំនួនសេវាតាមឆ្នាំ | | | | សរុប |
|---|---|---|---|---|---|---|
| | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | |
| ១ | លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ | 190,319 | 239,812 | 424,714 | 377,426 | 1,232,271 |
| ២ | លិខិតបញ្ជាក់លំនៅ | 147,283 | 191,074 | 197,075 | 214,806 | 750,238 |
| ៣ | លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ | 311,926 | 337,444 | 350,357 | 281,505 | 1,281,231 |
| ៤ | លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី | 236,364 | 409,979 | 1,037,845 | 751,210 | 2,435,397 |
| ៥ | លិខិតបញ្ជាក់ទាយាទ | 22,585 | 34,265 | 51,813 | 40,269 | 148,932 |
| ៦ | លិខិតបញ្ជាក់កិរិយាមាយាទ | 42,751 | 54,191 | 99,040 | 84,242 | 280,224 |
| ៧ | លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប | 33,751 | 39,360 | 46,928 | 39,866 | 159,905 |
| ៨ | លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ(គិតជាក្បាល) | 26,349 | 35,015 | 49,256 | 38,336 | 148,956 |
| ៩ | លិខិតបញ្ជាក់តបណ្ដាញអគ្គិសនី | 16,657 | 19,523 | 32,608 | 35,655 | 104,443 |

| ល.រ. | បរិយាយ | ចំនួនសេវាតាមឆ្នាំ | | | | សរុប |
|---|---|---|---|---|---|---|
| | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | |
| ១០ | លិខិតបញ្ជាក់តបណ្ដាញទឹកស្អាត | 13,762 | 19,942 | 20,732 | 20,146 | 74,582 |
| ១១ | លិខិតបញ្ជាក់ជួលដី ផ្ទះតូប យានជំនិះ | 20,283 | 25,870 | 35,751 | 30,060 | 111,964 |
| ១២ | លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ | 10,425 | 10,792 | 24,106 | 25,851 | 71,174 |
| ១៣ | បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត (លិខិតដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) | 343,756 | 444,157 | 730,315 | 733,237 | 2,251,465 |
| **សរុបរួម** | | **1,416,211** | **1,861,424** | **3,100,540** | **2,672,609** | **9,050,782** |

២.១១.២ ការផ្តល់សេវាផ្សេងៗ

ក្រៅពីការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយ រដ្ឋបាលឃុំ សង្កាត់ ក៏មានភារកិច្ចដឹកនាំ និងសម្របសម្រួលយន្តការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងក្រុមជនងាយរងហានិភ័យប្រកបដោយសុក្រឹតភាព និងតម្លាភាព សំដៅធានាថាប្រជាពលរដ្ឋគោលដៅអាចទទួលបានបណ្ណសមធម៌បានទាន់ពេលវេលា។ លើសពីនេះ រដ្ឋបាលឃុំ សង្កាត់ ក៏មានតួនាទីចុះផ្សព្វផ្សាយផ្ទាល់ដល់ខ្នងផ្ទះប្រជា-ពលរដ្ឋអំពីកម្មវិធីជាតិជំនួយសង្គមផ្សេងៗ កិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺដើម្បីធានាឱ្យបាននូវការផ្តល់សេវាប្រកបដោយសមធម៌ គុណភាព និងបរិយាបន្ន ដោយប្រកាន់ខ្ជាប់ជានិច្ចនូវស្មារតី «មិនបោះបង់ពលរដ្ឋខ្មែរណាម្នាក់»។

ជាងនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្ទេរមុខងារគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ឱ្យស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់រដ្ឋបាលឃុំ សង្កាត់។ ការអប់រំកុមារតូច ជាពិសេសតាមរយៈ មត្តេយ្យសិក្សាសហគមន៍ ពិតជាមានសារៈសំខាន់បំផុតក្នុងការកសាងមូលធនមនុស្ស និងធានាឱ្យកុមារមានការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ទាំងផ្នែកបញ្ញា ស្មារតី និងសុខភាព និងសង្គម មុនពេលចូលរៀនថ្នាក់បឋមសិក្សា។ មត្តេយ្យសិក្សាសហគមន៍ក៏បានចូលរួមសម្រាលបន្ទុកមាតាបិតា ជាពិសេសស្ត្រី ដោយផ្តល់ឱកាសឱ្យពួកគេអាចចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងបង្កើនប្រាក់ចំណូល ខណៈដែលកុមារទទួលបានការថែទាំ និងអប់រំប្រកបដោយសុវត្ថិភាពនៅក្នុងសហគមន៍។ សម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥ នេះ ចំនួនមត្តេយ្យសហគមន៍ទូទាំងប្រទេសមានចំនួន ៣.៣៤៨ កន្លែង ដែលមានទីតាំង១.១១៩ ឃុំ សង្កាត់ ក្នុងចំណោម ១.៦៥២ ឃុំ សង្កាត់។

បន្ថែមលើសពីនេះ រដ្ឋបាលឃុំ សង្កាត់ក៏មានតួនាទីសំខាន់នៅក្នុងការចូលរួមអនុវត្តលើកកម្ពស់សេវាថែទាំសុខភាពបឋមនៅតាមមូលដ្ឋានតាមរយៈគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព ដែលមានមេឃុំ ឬចៅសង្កាត់ជាប្រធាន ព្រមទាំងចូលរួមជាគណៈកម្មាធិការគ្រប់គ្រងសាលារៀនផងដែរ។

## ២.១២-ការសម្រុះសម្រួលនិងការដោះស្រាយវិវាទនៅមូលដ្ឋាន

ការសម្រុះសម្រួល និងដោះស្រាយវិវាទនៅមូលដ្ឋាន ដែលតែងតែកើតមានឡើងនៅតាមភូមិនីមួយៗ គឺជាភារកិច្ចដ៏សំខាន់មួយក្នុងចំណោមភារកិច្ចដ៏ទៃទៀតរបស់រដ្ឋបាលឃុំ សង្កាត់ ។ ក្នុងករណីដែលភាគីជម្លោះមិនទទួលយកការសម្រុះសម្រួលរបស់រដ្ឋបាលឃុំ សង្កាត់ទេ រដ្ឋបាលឃុំ សង្កាត់នឹងបញ្ជូនបន្តដល់សមត្ថកិច្ចពាក់ព័ន្ធ ដើម្បីដោះស្រាយបន្ត។

ចាប់ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៥ រដ្ឋបាលឃុំ សង្កាត់បានទទួលបានសំណើដោះស្រាយទំនាស់មានចំនួនសរុប **២៣០.៤៨១ ករណី** ដែលមានន័យថាជាមធ្យមឃុំ សង្កាត់នីមួយៗទទួលសំណើដោះ-ស្រាយទំនាស់ចំនួន ៣៥ ករណីក្នុងមួយឆ្នាំៗ។ ក្នុងចំណោមទាំងនោះ ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់មានចំនួនសរុប **២១៥.៧១៣ (៩៣%)** និងករណីដែលបានបញ្ជូនបន្តទៅសមត្ថកិច្ចពាក់ព័ន្ធមានចំនួន **១៤.៧៦៨ (៧%)**។ លទ្ធផលនេះបានបញ្ជាក់ថា យន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធនេះនៅថ្នាក់ឃុំ សង្កាត់នេះ ពិតជាបានរួមចំណែកយ៉ាងសំខាន់ក្នុងការទប់ស្កាត់ពិតជាបានរួមចំណែកជួយកាត់បន្ថយការរីករាលដាលជម្លោះ។

### ២.១០ បណ្តឹងឬទំនាស់នៅរដ្ឋបាលឃុំ សង្កាត់

| ល.រ. | បរិយាយ | ចំនួនករណីតាមឆ្នាំ | | | | សរុប |
|---|---|---|---|---|---|---|
| | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | |
| **ក** | **ការដោះស្រាយវិវាទសម្រាប់រដ្ឋបាលឃុំ សង្កាត់** | | | | | |
| ១ | ករណីទំនាស់ដែលឃុំ សង្កាត់បានទទួល | 49,827 | 54,840 | 66,874 | 58,940 | 230,481 |
| ២ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់ | 46,609 | 51,318 | 62,785 | 55,001 | 215,713 |
| ៣ | ករណីដែលបានបញ្ជូនទៅសមត្ថកិច្ចបន្តឬស្ថាប័នពាក់ព័ន្ធ | 3,218 | 3,522 | 4,089 | 3,939 | 14,768 |

## ២.១៣-ការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការចុះឈ្មោះអ្នកបោះឆ្នោត

ផ្អែកតាមមាត្រា៥០ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រតិភូកម្មឱ្យបំពេញតួនាទីតំណាងឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតនិងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់។ លើមូលដ្ឋាននេះ រដ្ឋបាលឃុំ សង្កាត់បានធ្វើបច្ចុប្បន្ន-ភាពជាប្រចាំឆ្នាំលើការពិនិត្យឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ គិតត្រឹមឆ្នាំ២០២៥នេះ ចំនួនប្រជាពលរដ្ឋសរុបដែលមានឈ្មោះក្នុងបញ្ជីចុះឈ្មោះបោះឆ្នោតគឺ ១០.១៦២.២៣២ នាក់។

### តារាង២.១១ ការពិនិត្យនិងការចុះឈ្មោះអ្នកបោះឆ្នោត

| ល.រ. | បរិយាយ | ឆ្នាំ | | | |
|---|---|---|---|---|---|
| | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
| ១ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មីក្នុងបញ្ជីបោះឆ្នោត | 592,087 | 233,772 | 177,568 | 223,908 |

| ល.រ. | បរិយាយ | ឆ្នាំ | | | |
|---|---|---|---|---|---|
| | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីចុះឈ្មោះអ្នកបោះឆ្នោត | 271,142 | 120,883 | 11,889 | 163,034 |
| ៣ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះក្នុងបញ្ជីចុះឈ្មោះបោះឆ្នោត | 9,710,655 | 9,871,495 | 9,992,421 | 10,162,232 |

សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៧ គ.ជ.ប បានចាប់ផ្តើមចែកលិខិតអញ្ជើញ(ប័ណ្ណព័ត៌មាន)អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២៥ ចាប់ថ្ងៃទី៧ ខែកញ្ញា ដល់ថ្ងៃទី៦ ខែតុលាឆ្នាំ២០២៦ និងចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតចាប់ពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៦ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦។

## ២.១៤-ការកសាងសមត្ថភាពនិងការបណ្តុះបណ្តាល

បន្ទាប់ពីប្រកាសចូលកាន់តំណែង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់បានទទួលនូវការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់លើប្រធានបទជាច្រើន ដែលត្រូវបានរៀបចំឡើងដោយរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រសួង ស្ថាប័ន សាលាជាតិរដ្ឋបាលមូលដ្ឋាន ឬអង្គការសមាគម។

ចាប់ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៥ រដ្ឋបាលឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងបុគ្គលិករបស់ឃុំ សង្កាត់បានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗចាប់ពី១ថ្ងៃឡើងដែលត្រូវបានគាំទ្រពីថ្នាក់ជាតិ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ទីរជំនាញ និងអង្គការសមាគម សរុបប្រមាណ១៤៤.៣៣៧ វគ្គ។ គិតជាមធ្យមរដ្ឋបាលឃុំ សង្កាត់នីមួយៗទទួលបានវគ្គសិក្សាឬបណ្តុះបណ្តាលប្រមាណ ២២វគ្គ ក្នុងរយៈពេល១ឆ្នាំ។

**តារាង ២.១២ វគ្គបណ្តុះបណ្តាលសម្រាប់រយៈពេល១ថ្ងៃឡើង**

| ល.រ. | ស្ថាប័នឬអង្គភាព | ចំនួនវគ្គដែលបានទទួលតាមឆ្នាំ | | | | សរុប |
|---|---|---|---|---|---|---|
| | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | |
| ១ | រដ្ឋបាលថ្នាក់ជាតិ | 1,942 | 2,155 | 2,743 | 3,360 | 10,200 |
| ២ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | 10,109 | 11,339 | 13,266 | 14,884 | 49,598 |
| ៣ | រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ | 10,165 | 11,397 | 12,805 | 14,322 | 48,689 |
| ៤ | រដ្ឋបាលឃុំ សង្កាត់សាមី | 1,133 | 1,236 | 1,509 | 1,588 | 5,461 |
| ៥ | សមាគមរដ្ឋបាលថ្នាក់ក្រោមជាតិ | 2,099 | 2,156 | 2,587 | 2,815 | 9,657 |
| ៦ | ដៃគូរ អង្គការសង្គមស៊ីវិលនានា | 4,371 | 4,812 | 5,407 | 6,142 | 20,732 |
| **សរុប** | | **29,819** | **33,095** | **38,317** | **43,111** | **144,337** |

## ២.១៥ ការងារឌីជីថល

ដោយនៅក្នុងអាណត្តិទី៥ នៃក្រុមប្រឹក្សាឃុំ សង្កាត់នេះគឺជាអាណត្តិមួយស្ថិតនៅក្នុងយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា ដូច្នេះការរៀបចំការងារឌីជីថលនៅថ្នាក់ឃុំ សង្កាត់ក៏ត្រូវបានគិតគូរ និងរៀបចំផងដែរ។ ក្នុងអាណត្តិទី៥ នេះ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានគ.ជ.អ.ប. បានរៀបចំឱ្យមានប្រព័ន្ធឌីជីថលមួយចំនួនសម្រាប់ការគ្រប់គ្រងនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ រួមមាន៖

- ប្រព័ន្ធឯកសារឌីជីថល FMIS Portal ដើម្បីស្វែនលិខិតយុត្តាធិការចំណាយសម្រាប់មុខសញ្ញាចំណាយថវិកាក្នុងក្របខណ្ឌរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
- ប្រព័ន្ធតាមដានថវិការដ្ឋបាលឃុំ សង្កាត់
- កម្មវិធីទូរស័ព្ទដៃស្ដីពីគណនេយ្យភាពសង្គម (SA Mobile App) ក៏បានដាក់ឱ្យប្រើ

## ២.១៦-ការងារគណនេយ្យភាពសង្គម



នៅក្នុងអាណត្តិទី៥ នៃក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់បានចូលរួមអនុវត្តការងារគណនេយ្យភាពសង្គម ក្នុងគោលបំណងដើម្បីធានាឱ្យប្រជាពលរដ្ឋទទួលបាននូវព័ត៌មាននានា អំពីសិទ្ធិ ស្តង់ដាការបំពេញការងារ ការគ្រប់គ្រងថវិកា និងផ្តល់ឱកាសដល់ប្រជាពលរដ្ឋសម្តែងនូវមតិយោបល់ និងចូលរួមតាមដានការបំពេញការងាររបស់មន្ត្រី បុគ្គលិកអង្គភាពផ្តល់សេវានានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតលើសេវានៅមូលដ្ឋានចំនួន០៣គឺ៖ (១).ការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (២).ការផ្តល់សេវានៅសាលាបឋមសិក្សា និង (៣).ការផ្តល់សេវានៅមណ្ឌលសុខភាព។ ការងារទាំងនេះ ជាតថភាពឆ្លុះបញ្ចាំងនូវការលើកកម្ពស់ការទទួលខុសត្រូវ គណនេយ្យភាព តម្លាភាព និងក្រម-សីលធម៌ការងាររបស់បុគ្គលិកដែលកំពុងផ្តល់សេវានៅរដ្ឋបាលឃុំ សង្កាត់ មណ្ឌលសុខភាព សាលាបឋមសិក្សា ស្របតាមតួនាទីនិងភារកិច្ចដែលបានកំណត់ក្នុងលិខិតបទដ្ឋាននានា។

ការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ បាននិងកំពុងគ្របដណ្តប់ លើការផ្តល់សេវារបស់រដ្ឋបាលឃុំ សង្កាត់ចំនួន ១.៥៥០ (ស្មើនឹង ៩៤% នៃចំនួនរដ្ឋបាលឃុំ សង្កាត់សរុប ១.៦៥២) សាលាបឋមសិក្សាចំនួន ៦.៩២២ (ស្មើនឹង ៩៤% នៃចំនួនសាលាបឋមសិក្សាសរុប ៧.៧២១) និងមណ្ឌលសុខភាពចំនួន ១.២៥៦ (ស្មើនឹង ៩៦% នៃចំនួនមណ្ឌលសុខភាពសរុប ១.៣១៣) ដែលស្ថិតនៅក្នុងដែនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន១៩០ នៃ២៥ រាជធានី ខេត្តទូទាំងប្រទេស។

ជាលទ្ធផល ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានអនុវត្តការងារគណនេយ្យភាពបានបិទផ្សាយអំពីស្តង់ដានៃការបំពេញការងារ ការគ្រប់គ្រងថវិកាតាមរយៈផ្ទាំងព័ត៌មានសម្រាប់ប្រជាពលរដ្ឋ នៅតាមក្តារខៀន

ព័ត៌មាននៅសាលាឃុំ សង្កាត់ និងតាមទីសាធារណៈនានា ដើម្បីឱ្យប្រជាពលរដ្ឋអាចតាមដាននូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាចធ្វើការវាយតម្លៃបាននូវការបំពេញការងារក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានបោះឆ្នោតដោយប្រជាពលរដ្ឋរបស់ខ្លួន។ ដើម្បីងាយស្រួលដល់ប្រជាពលរដ្ឋ កម្មវិធីផ្ទាំងព័ត៌មាននេះ ក៏ត្រូវបានរៀបចំជា APP អនឡាញ ដែលប្រជាពលរដ្ឋអាចមើលតាមទូរសព្ទដៃ និងឧបករណ៍ឌីជីថលផ្សេងៗទៀត។

### ២.១៧-ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព

ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលលេខ០១ គ.ន.ប. ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព រដ្ឋបាលឃុំ សង្កាត់បានខិតខំយកចិត្តទុកដាក់ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងដាក់បញ្ចូលនូវសកម្មភាពនិងថវិកាសម្រាប់ការងារភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ទៅក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់ដែលមានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ជាសេនាធិការ និងកម្លាំងប្រជាការពារ បានផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព នៅតាមខ្នងផ្ទះ ភូមិ និងសហគមន៍ ព្រមទាំងវេទិកានានា។

ជាមួយគ្នានេះរដ្ឋបាលឃុំ សង្កាត់នីមួយៗបានចូលរួមក្នុងកម្មវិធីប្រលងប្រណាំងអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពជាប្រចាំឆ្នាំដែលបានផ្តោតជាសំខាន់លើលក្ខណសម្បត្តិទី២ ទី៣ និងទី៤នៃគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថភាព និងក្រោមក្របខណ្ឌអនុវត្តរបស់ក្រសួងមហាផ្ទៃ។ រដ្ឋបាលឃុំ សង្កាត់ណាដែលទទួលបានចំណាត់ថ្នាក់ចាប់ពីលេខ១ដល់លេខ៣ ត្រូវបានការលើកសរសើរនិងថវិកាលើកទឹកចិត្តពីក្រសួងមហាផ្ទៃ។ ចាប់ពីឆ្នាំ ២០២២-២០២៥ ជាមធ្យមឃុំ សង្កាត់ចំនួន **១.២៤៣** ទទួលបានចំណាត់ថ្នាក់លេខ១ ឃុំ សង្កាត់ចំនួន **៣៦៤** ទទួលបានចំណាត់ថ្នាក់លេខ២ និងឃុំ សង្កាត់ចំនួន **៤១** ទទួលបានចំណាត់ថ្នាក់លេខ៣។

**២.១៣ ចំណាត់ថ្នាក់ឃុំ សង្កាត់ ក្នុងការការប្រលងប្រណាំងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព**

| ចំណាត់ថ្នាក់ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ជាមធ្យម |
|---|---|---|---|---|---|
| ១ | 1,242 | 1,117 | 1,139 | 1,474 | 1,243 |
| ២ | 368 | 451 | 475 | 163 | 364 |
| ៣ | 38 | 75 | 34 | 15 | 41 |
| **សរុប** | 1,648 | 1,643 | 1,648 | 1,652 | |

### ២.១៨-សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ឬហៅថាសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ជាសមាគមក្រុមប្រឹក្សាមួយប្រភេទក្នុងចំណោមសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីលើកកម្ពស់ពង្រឹងសិទ្ធិអំណាចនិងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យកាន់តែប្រសើរក្នុងភាពជាម្ចាស់ឆ្នោត ឬជាតំណាងប្រជាពលរដ្ឋមូលដ្ឋាន សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានបានចូលរួមក្នុងសកម្មភាពជាច្រើនក្នុងអាណត្តិទី៥នៃក្រុមប្រឹក្សាឃុំ សង្កាត់ ដូចជាការបណ្តុះបណ្តាលបេក្ខនារីឈរឈ្មោះ

បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កិច្ចការទំនាក់ទំនងសាធារណៈ និងការឃោសនាស្វែងរកសំឡេងគាំទ្រតាមរយៈការបោះឆ្នោត ការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាជាស្ត្រី និងអំពីអភិបាលកិច្ចមូលដ្ឋាន និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ព្រមទាំងការគាំទ្រថវិកាមួយចំនួនសម្រាប់បណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ សង្កាត់ទើបជាប់ឆ្នោតនៅអាណត្តិទី៥កន្លងទៅផងដែរ។

ទន្ទឹមនឹងនេះ តាមរយៈគម្រោងភាពជាដៃគូសម្រាប់គំនិតច្នៃប្រឌិតរបស់ទីក្រុងលើការដឹកនាំរបស់ស្ត្រីនៅមូលដ្ឋានដែលគាំទ្រពីរដ្ឋាភិបាលនៃប្រទេសកាណាដា និងសហព័ន្ធទីក្រុងនៃប្រទេសកាណាដា សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានបានខិតខំ និងយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តកម្មវិធីពានរង្វាន់ស្ត្រីឆ្នើមក្នុងការដឹកនាំនៅមូលដ្ឋាន។ បេក្ខភាពជាស្ត្រីដែលជាអភិបាលក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ជាស្ត្រី នៅទូទាំងប្រទេសត្រូវបានចូលរួមប្រកួតប្រជែងក្នុងកម្មវិធីពានរង្វាន់ស្ត្រីឆ្នើមសម្រាប់ជ័យលាភី។ ជាលទ្ធផលនៅក្នុងឆ្នាំ២០២៤ មេឃុំមួយរូបទទួលបានជ័យលាភីទី១ ចៅសង្កាត់មួយរូបទទួលបានជ័យលាភីទី២ និងចៅសង្កាត់មួយទៀតទទួលបានជ័យលាភីទី៣ ហើយឆ្នាំ២០២៥ សមាជិកាក្រុមប្រឹក្សាក្រុងមួយរូបទទួលបានជ័យលាភីទី១ និងចៅសង្កាត់មួយរូបទៀតទទួលបានជ័យលាភីទី២។

## ៣-បញ្ហាប្រឈម និងអនុសាសន៍

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលគួរជាមោទនៈខាងលើនេះ រដ្ឋបាលឃុំ សង្កាត់ដែលដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៥ក៏បានជួបប្រទះនូវបញ្ហាប្រឈមចម្បងៗមួយចំនួន រួមមាន ៖

**១.សមត្ថភាព និងធនធានមនុស្ស៖** ក្នុងអាណត្តិទី៥ នេះមានការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត យន្តការជាច្រើន និងកិច្ចការនានាតាមប្រព័ន្ធឌីជីថល។ ការណ៍នេះបានធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិករបស់ខ្លួន រួមទាំងមន្ត្រីភូមិ ត្រូវខិតខំស្វែងយល់នូវការប្រែប្រួលថ្មីៗបន្ថែមទៀត ខណៈដែលការយល់ដឹងពីការកែប្រែនេះនៅមានកម្រិត ស្របពេលដែលការបណ្តុះបណ្តាល និងការផ្សព្វផ្សាយមិនសូវបានទូលំទូលាយ។ ជាក់ស្តែង កន្លងមកស្មៀនបានទទួលការបណ្តុះបណ្តាលផ្លូវការម្តងគត់ពាក់ព័ន្ធនឹងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ចាប់តាំងពីចាប់ផ្តើមបង្កើតឱ្យមានស្មៀនឃុំ សង្កាត់ដំបូងមក ដើម្បីយកទៅអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។ ស្រដៀងគ្នានេះ ដែរមន្ត្រីភូមិ ក៏មិនដែលទទួលការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការអនុវត្តតួនាទីភារកិច្ច គឺភាគច្រើនផ្អែកលើគោលការណ៍រៀនបណ្តើរធ្វើបណ្តើរ។ បើទោះជាមានការបណ្តុះបណ្តាលមួយចំនួនមែន តែជាការបណ្តុះបណ្តាលបែបបន្ទាន់ ឬចំពោះកិច្ច លើកិច្ចការជាក់លាក់ណាមួយ ដោយមិនមានការរៀបចំជាប្រព័ន្ធ ឬជាប្រចាំឱ្យបានច្បាស់លាស់ ក្នុងការគាំទ្រដល់មន្ត្រីនៅមូលដ្ឋានទាំងនេះឡើយ។

កត្តាដូចបានរៀបរាប់ខាងលើនេះ ទាមទារឱ្យមានការកសាងសមត្ថភាព ជាប្រចាំ និងឱ្យបានទូលំទូលាយដល់អ្នកអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ដោយរៀបចំឱ្យមានកម្មវិធីសិក្សាច្បាស់លាស់ សម្រាប់បណ្តុះបណ្តាលដល់មន្ត្រីនៅមូលដ្ឋានទាំងនោះ។ បច្ចុប្បន្ននេះ កម្មវិធីសិក្សាសម្រាប់ស្មៀនគឺត្រូវបានរៀបចំរួចរាល់ ដែលត្រូវទទួលការបណ្តុះបណ្តាលនៅសាលាជាតិរដ្ឋបាលមូលដ្ឋាន។ ដោយឡែក សម្រាប់មន្ត្រីភូមិគឺ មិនមានយន្តការ ឬកម្មវិធីសិក្សាអ្វីច្បាស់លាស់នៅឡើយទេ សម្រាប់ការកសាងសមត្ថភាពរបស់មន្ត្រីភូមិ ដើម្បីឱ្យមន្ត្រីភូមិអាចអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាព។

ទន្ទឹមនេះ រាល់ការការអនុវត្តគោលនយោបាយ កម្មវិធី និងសកម្មភាពរបស់ថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរវិស័យ គឺត្រូវបានអនុវត្តនៅមូលដ្ឋាន ហើយចុងក្រោយត្រូវធ្លាក់លើឃុំ សង្កាត់ ខណៈដែលរដ្ឋបាលឃុំ សង្កាត់មានធនធានមនុស្សមិនគ្រប់គ្រាន់។ ដូច្នេះ ក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលរាជធានី ខេត្ត មន្ទីរវិស័យ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវគិតគូរដល់ការផ្តល់ទាំងបច្ចេកទេស ធនធានមនុស្ស និងធនធានថវិកាឱ្យបានគ្រប់គ្រាន់ នៅពេលដែលតម្រូវឱ្យមានការចូលរួមពីរដ្ឋបាលឃុំ សង្កាត់នៅក្នុងការអនុវត្ត។

**២. ការរៀបចំផែនការអភិវឌ្ឍ៖** ការរៀបចំផែនការអភិវឌ្ឍប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់ពុំទាន់ឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋានរបស់ប្រជាពលរដ្ឋនៅឡើយ ដោយសារដំណើរការនៃការរៀបចំផែនការមាននីតិវិធីច្រើន ដែលធ្វើឱ្យរដ្ឋបាលឃុំ សង្កាត់ ដែលមន្ត្រីមានចំនួនតិចផងមានការលំបាក ក្នុងការរៀបចំផែនការទាំងនេះ ទៅតាមគោលការណ៍ណែនាំ ដែលត្រូវចំណាយពេលវេលាច្រើន។ ជាមួយគ្នានេះ ក្នុងការងារកសាងនិងរៀបចំកម្មវិធិនិយោគបីឆ្នាំរំកិលរដ្ឋបាលឃុំ សង្កាត់ សកម្មភាពនៃសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ ក៏ពុំសូវមានការគាំទ្រពីអ្នកពាក់ព័ន្ធ។ លើមូលដ្ឋាននេះ ដើម្បីជានាបាននូវប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃដំណើរការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ទាមទារឱ្យមានពិនិត្យនិងសិក្សាឡើងវិញនូវគោលការណ៍ណែនាំ នីតិវិធី និងយន្តការរៀបចំផែនការនិងថវិកាឃុំ សង្កាត់ឱ្យមានលក្ខណៈសាមញ្ញ មានការចូលរួម មាននវានុវត្តន៍ ព្រមទាំងផ្សារភ្ជាប់នឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិផងដែរ។

**៣. ការចូលរួមរបស់ប្រជាពលរដ្ឋ៖** បើទោះជារាជរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំ សង្កាត់ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការអនុវត្តកិច្ចការនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ការចូលរួមផ្ទាល់របស់ប្រជាពលរដ្ឋនៅតែមានកម្រិត។ និន្នាការនៃការធ្លាក់ចុះការចូលរួមផ្ទាល់នេះមិនមែនតែនៅក្នុងបរិបទនៅក្នុងប្រទេសកម្ពុជានោះ វាស្ទើរតែជានិន្នាការសាកល ដោយសារប្រជាពលរដ្ឋមានកិច្ចការរវល់នៅក្នុងការប្រកបមុខរបរ ដើម្បីជីវភាពរបស់ខ្លួន។ ដូច្នេះការជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងកិច្ចការនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែមានភាពនវានុវត្តន៍ ឱ្យស្របទៅតាមស្ថានភាពបច្ចុប្បន្ន។

**៤. គម្រោងមូលនិធិឃុំ សង្កាត់៖** នៅក្នុងការរៀបចំ និងអនុវត្តគម្រោងឃុំ សង្កាត់ គឺតម្រូវឱ្យអនុវត្តស្របតាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដើម្បីជានាបាននូវតម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ ទោះយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង នៅក្នុងអាណត្តិទី៥នេះ ការអនុវត្តគម្រោងឃុំ សង្កាត់មួយចំនួនមិនបានអនុវត្តស្របតាមសៀវភៅណែនាំខាងលើ និងកើតមានភាពមិនប្រក្រតីនៅពេលដេញថ្លៃ និងពេលអនុវត្តគម្រោង ដែលធ្វើឱ្យមានប្រតិកម្មពីសារណៈជនទូទៅ បណ្តាសារព័ត៌មាន និងបណ្តាញសង្គម ជាពិសេសពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។

ក្នុងរយៈពេលខ្លីខាងមុខនេះ និងដោយរដ្ឋបាលរាជធានី ខេត្ត ដែលត្រូវបានប្រតិភូកម្ម ដោយក្រសួងមហាផ្ទៃរួចហើយនោះ ត្រូវបន្តពង្រឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងឃុំ សង្កាត់ និងចាត់វិធានការឱ្យបានម៉ឺងម៉ាត់ដល់អ្នកពាក់ព័ន្ធនឹងការអនុវត្តភាពមិនប្រក្រតី រួមទាំងការដាក់បញ្ជីខ្មៅដល់ក្រុមហ៊ុនទាំងឡាយ ដែលបានគប់គិតគ្នាប្រព្រឹត្តអំពើពុករលួយ។ ក្នុងរយៈពេលវែង ដើម្បីឱ្យការគាំទ្រក្នុងការអនុវត្តគម្រោងឃុំ សង្កាត់កាន់តែមានភាពល្អប្រសើរ គួរពិចារណាធ្វើប្រតិភូកម្មការងារគាំទ្រលើការរៀបចំ និងការអនុវត្តគម្រោងឃុំ សង្កាត់ ទៅដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលជារដ្ឋបាលនៅកៀកនឹង

រដ្ឋបាលឃុំ សង្កាត់ ហើយទទួលខុសត្រូវលើចំនួនឃុំ សង្កាត់ តិចជាងចំនួនឃុំ សង្កាត់ ដែលទទួលខុសត្រូវដោយរដ្ឋបាលរាជធានី ខេត្ត។

ទន្ទឹមនេះ គួររៀបចំឱ្យមានមន្ត្រីបច្ចេកទេសមួយរូប ដែលជាមន្ត្រីផ្អែកលើកិច្ចព្រមព្រៀង ឬក៏ពង្រឹងការិយាល័យជំនាញលើការងារគម្រោងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីជួយជាជំនួយបច្ចេកទេសនៅក្នុងការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។ បន្ថែមពីនេះ គួរមានការពិនិត្យឡើងវិញនូវនីតិវិធីមួយចំនួននៅក្នុងដំណើរការរៀបចំ និងអនុវត្តគម្រោងឃុំ សង្កាត់ ដើម្បីជួយគាំទ្រដល់ការរៀបចំ និងការអនុវត្តគម្រោងកាន់តែមានតម្លាភាព ប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

**៥. ថវិកាឃុំ សង្កាត់៖** កន្លងមកនេះ ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ក្នុងឆ្នាំនីមួយៗមានភាពយឺតយ៉ាវ ព្រោះការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ត្រូវរង់ចាំដល់ការវិភាជថវិកាត្រីមាសទី៣ទើបមានថវិកាគ្រប់គ្រាន់សម្រាប់ឱ្យរដ្ឋបាលឃុំ សង្កាត់មានលទ្ធភាពអនុវត្តគម្រោងនិងធ្វើការទូទាត់ថវិកាជូនអ្នកទទួលការបានទាន់ពេលវេលា និងត្រឹមត្រូវតាមកិច្ចសន្យាគម្រោង។ ដូច្នេះ ដើម្បីលើកកម្ពស់ការអនុវត្តគម្រោងទាំងនេះប្រកបដោយប្រសិទ្ធភាពទាំងបរិមាណ និងគុណភាព ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានគ.ជ.អ.ប. គួរសហការ ក្នុងការជំរុញការផ្ទេរធនធានថវិកាឃុំ សង្កាត់ (ផ្នែកអភិវឌ្ឍន៍មូលដ្ឋាន) ពី ៤លើក មកត្រឹម ២ លើក ដើម្បីឱ្យរដ្ឋបាលឃុំ សង្កាត់មានលទ្ធភាពក្នុងការអនុវត្តគម្រោងបានទាន់ពេលវេលា។ ជាមួយគ្នានេះ គួរបង្កើនថវិកាបន្ថែមទៀតដល់រដ្ឋបាលឃុំ សង្កាត់ ជាពិសេសផ្នែកអភិវឌ្ឍន៍មូលដ្ឋាន តាមរយៈការបង្កើតឱ្យមានប្រភពចំណូលផ្ទាល់នានា បន្ថែមទៀត នៅមូលដ្ឋានដើម្បីអាចឱ្យរដ្ឋបាលឃុំ សង្កាត់អាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព ទាន់ពេលវេលា និងបរិយាបន្ន។

**៦. ឯកសារអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម៖** ឯកសារអត្រានុកូលដ្ឋានមួយចំនួននៅតែមានការខុសឈ្មោះ អក្ខរាវិរុទ្ធ ថ្ងៃខែឆ្នាំកំណើត ហើយការកែឯកការអត្រានុកូលដ្ឋាននេះចំណាយពេលវេលាយូរ។ ទន្ទឹមនេះ ការផ្តល់សន្លឹកបណ្ណអត្តសញ្ញាណបណ្ណ ក្រោយពីការថតរួចក៏មានភាពយឺតយ៉ាវដែរ។ ដូច្នេះ រដ្ឋបាលឃុំ សង្កាត់គួរខិតខំយកចិត្តទុកដាក់ឱ្យបានម៉ត់ចត់ក្នុងការចេញឯកសារអត្រានុកូដ្ឋាន និងធ្វើការផ្សព្វផ្សាយអំពីនីតិវិធីរៀបចំឯកសារអត្រានុកូដ្ឋានឱ្យបានទូលំទូលាយ។ ទន្ទឹមនេះ ស្នើជួយជំរុញការកែតម្រូវសំបុត្រអត្រានុកូលដ្ឋាន ឱ្យនិងការរៀបចំផ្តល់អត្តសញ្ញាណបណ្ណឱ្យបានឆាប់រហ័ស។

**៧. ការចុះបញ្ជីដីធ្លី និងការផ្ទេរកម្មសិទ្ធិ៖** ការចុះបញ្ជីដីនៅឃុំខ្លះមិនទាន់បានរលូន ដូចជាដីធ្លីកន្លែងខ្លះមិនទាន់ចុះបញ្ជីជាប្រព័ន្ធ។ ម្យ៉ាងវិញទៀត ដំណើរការនៃការផ្ទេរកម្មសិទ្ធិចំណាយពេលវេលាយូរហើយទំនាស់ដីធ្លីខ្លះមិនទាន់ដោះស្រាយបាន ព្រមទាំងមានការសង់លំនៅដ្ឋានលើផ្លូវសាធារណៈ។ បញ្ហាទាំងនេះជាបញ្ហាស្មុគស្មាញមួយសម្រាប់រដ្ឋបាលឃុំ សង្កាត់ដែលទាមទារឱ្យមានកិច្ចសហការជាមួយស្ថាប័នជំនាញ និងការណែនាំនិងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានពាក់កិច្ចការដីធ្លីដល់សាធារណជនឱ្យបានទូលំទូលាយ។

**៨. ការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយ៖** កន្លែងផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលឃុំ សង្កាត់ ពុំទាន់មានកន្លែងរៀបចំឱ្យសមស្រប។ ម្យ៉ាងវិញទៀត ការចេញទម្រង់លិខិតបញ្ជាក់ខ្លះខុសៗគ្នារវាងរដ្ឋបាលឃុំ សង្កាត់ខ្លះ និងសេវាខ្លះរដ្ឋបាលឃុំ សង្កាត់មិនអាចចេញជូនប្រជាជនព្រោះគ្មានគោលការណ៍ណែនាំ។ កត្តាទាំងនេះទាមទារនូវការគាំទ្រពីស្ថាប័នមានសមត្ថកិច្ច នៅក្នុងការលើក

កម្ពស់រៀបចំទីតាំងផ្តល់ និងសម្ភារៈសមស្របប្រកបដោយសោណភាព ការដាក់ចេញនូវគោលការណ៍នានា និងជំរុញការផ្សព្វផ្សាយព័ត៌មានសេវារដ្ឋបាលឃុំ សង្កាត់នៅតាមភូមិ សហគមន៍ និងទីប្រជុំជន ឱ្យបានទូលំទូលាយ។

**៩. ហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយចំនួននៅខ្វះខាត៖** ឃុំ សង្កាត់ ជាពិសេសឃុំ សង្កាត់ដែលមិនមែនជាទីប្រជុំជន នៅតែបន្តប្រឈមបញ្ហាការខ្វះទឹកស្អាត ភ្លើងអគ្គិសនី និងផ្លូវសមរម្យសម្រាប់ការធ្វើដំណើរ។ ការណ៍នេះបានធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាតំណាងប្រជាពលរដ្ឋមានការលំបាកក្នុងការប្រឈមជាមួយពលរដ្ឋ ដោយសារថវិការបស់ខ្លួនមានកំណត់ ដែលមិនអាចបំពេញសំណើរបស់ប្រជាពលរដ្ឋនៅក្នុងការស្នើសុំទឹកស្អាត ភ្លើងអគ្គសនី និងផ្លូវសមរម្យឱ្យបានគ្រប់គ្រាន់។ ក្នុងន័យនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ រួមទាំងរដ្ឋបាលក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ត្រូវខិតខំរួមគ្នាក្នុងការផ្តល់អាទិភាពលើការរៀបចំបណ្តាញទឹកស្អាត ភ្លើងអគ្គិសនី និងផ្លូវសមរម្យឱ្យបានគ្រប់គ្រាន់ ជាពិសេសនៅតាមឃុំ សង្កាត់ ដែលមិនមែនជាទីប្រជុំជន ឱ្យស្របទៅនឹងអាទិភាពគន្លឹះនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ «មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេក-វិទ្យា»។

**១០. ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថាន៖** គឺជាបញ្ហាដែលកើតឡើងស្ទើរគ្រប់ឃុំ សង្កាត់ ដូចជាបទល្មើសនេសាទ គ្រឿងស្រវឹងនិងគ្រឿងញៀន អំពើហិង្សាក្នុងគ្រួសារ ក្មេងទំនើង ការបោះឬទម្លាក់ចោលសំរាមនៅតាមដងផ្លូវ ទីសាធារណៈ ដងស្ទឹងឬព្រែក ការលែងសត្វពាហនៈនៅតាមទីសាធារណៈ គ្រោះថ្នាក់ចរាចរណ៍ ជាដើម។ បន្ថែមលើសពីនេះ កម្លាំងប៉ុស្តិ៍នគរបាលឃុំក៏មានចំនួនតិច ធ្វើឲ្យការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពជួបការលំបាក។ បញ្ហាទាំងអស់នេះ ទាមទារក្រសួង ស្ថាប័ន គណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប៉ុស្តិ៍នគរបាល និងអាជ្ញាធរពាក់ព័ន្ធចូលរួមសហការនិងគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ ក្នុងការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ គោលការណ៍ណែនាំ ក្រមសីលធម៌សង្គមឱ្យបានទូលំទូលាយ និងចាត់វិធានការឱ្យម៉ឺងម៉ាត់នៅក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា ដែលកើតមានឡើងនៅតាមមូលដ្ឋាន ព្រមទាំងចូលរួមជំរុញប្រជាពលរដ្ឋចូលរួមលើកកម្ពស់ អនាម័យនិងបរិស្ថាននៅតាមមូលដ្ឋានរបស់ខ្លួន ដើម្បីលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាពលរដ្ឋ។

ម្យ៉ាងវិញទៀត ប្រជាការពារដែលជាកម្លាំងនិងចលនាមូលដ្ឋានស្នូលក្នុងការរួមចំណែកអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព តែប្រជាការពារនេះហាក់ពុំទាន់មានយន្តការគាំទ្រច្បាស់លាស់នៅឡើយ ដូច្នេះគួរមានការសិក្សា និងមានយន្តការច្បាស់លាស់ក្នុងការគាំទ្រប្រជាការពារ នៅក្នុងការបន្តការអនុវត្តការងាររបស់ពួកគេ ជាពិសេសពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ឱ្យកាន់តែមានភាពល្អប្រសើរ។

## ៤. សេចក្តីសន្និដ្ឋាន

ជារួម ក្នុងរយៈពេលជាង ២៤ ឆ្នាំនេះ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ពិតជាបានរួមចំណែកដ៏សំខាន់នៅក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ការផ្តល់សេវាសាធារណៈ ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅមូលដ្ឋាន និងការរួមចំណែកកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមនឹងនេះ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការពិតជាបានផ្តល់អំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអំណាចបញ្ញត្តិ

និងអំណាចប្រតិបត្តិ ដើម្បីអាចឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អាចអនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងការបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ ដែលជាម្ចាស់ឆ្នោតប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធភាព។

ដោយឡែក ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ក៏បានខិតខំអនុវត្តតួនាទី ភារកិច្ច ដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងផ្តល់កិច្ចសហការ និងការគាំទ្រយ៉ាងច្រើនទៀត ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដោយសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈ តាមរយៈការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ ការអនុវត្តគម្រោងអភិវឌ្ឍន៍មូលដ្ឋាន ការអនុវត្តការងារសេវាសង្គមនិងអនាម័យបរិស្ថាន ការអនុវត្តការងារគណនេយ្យភាពសង្គម ការដោះស្រាយទំនាស់នៅមូលដ្ឋាន ការងារបោះឆ្នោត ការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ការអនុវត្តគោលនយោបាយគាំពារសង្គម និងការផ្តល់សេវាផ្សេងៗទៀត ដោយសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ។

ទោះយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ក៏នៅតែជួបប្រទះបញ្ហាប្រឈមដែលរួមមាន៖ បញ្ហាសមត្ថភាពនិងធនធានមនុស្ស បញ្ហារៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល បញ្ហាការអនុវត្តគម្រោងឃុំ សង្កាត់ បញ្ហាថវិកាឃុំ សង្កាត់នៅមានកម្រិត និងបញ្ហានៃការផ្តល់សេវាសាធារណៈផ្សេងៗ។ បញ្ហាប្រឈមទាំងនេះ ទាមទារមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដើម្បីរួមគ្នាដោះស្រាយ ដើម្បីជំរុញឱ្យការអនុវតតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់កាន់តែមានប្រសិទ្ធ-ភាព គណនេយ្យភាព និងឆ្លើយតប ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សំដៅរួមចំណែកក្នុងការប្រែក្លាយព្រះរាជាណាចក្រកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា
- លេខាធិការដ្ឋាននៃគ.ជ.អ.ប.
- ក្រសួងជាសមាជិកនៃគ.ជ.អ.ប.
- ឯកសារកាលប្បវត្តិ

## ឧបសម្ព័ន្ធទី១៖

# លិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ក្នុងក្របខណ្ឌ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ឆ្នាំ២០២២ដល់ឆ្នាំ២០២៥

| ល.រ. | លិខិតបទដ្ឋានគតិយុត្ត | ផ្សេងៗ |
|---|---|---|
| ១ | ព្រះរាជក្រឹត្យលេខ នស/រកត/០៦២២/ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីច្បាប់វិសោធនកម្ម មាត្រា១៤០នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ | ២០២២ |
| ២ | ប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃលេខ០០២ សហវ.ប្រក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ ស្ដីពីការជ្រើសរើស និងការកំណត់តួនាទី និងភារកិច្ចរបស់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ | - |
| ៣ | ប្រកាសលេខ១៨៣ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ដីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្ដីពីការអនុវត្តមុខងារនៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវជនីតិសម្បទា | - |
| ៤ | ប្រកាសលេខ៤៣៩៨ ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានសម្រាប់គាំទ្រការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព | - |
| ៥ | ប្រកាសលេខ៤៨០៧ ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ | - |
| ៦ | សេចក្ដីសម្រេចលេខ៤៦ ស.ស.រ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាល ស្ដីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់នីតិកាលទី៧ | - |
| ៧ | សេចក្ដីសម្រេចលេខ៦៤៧៣ ស.ស.រ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការតែងតាំងសមាសភាពថ្នាក់ដឹកនាំនិងក្រុមចំណុះលេខាធិការដ្ឋានសម្រាប់គាំទ្រការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព | - |
| ៨ | សេចក្ដីណែនាំរួមលេខ០០២ ស.ណ.ន. ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃនិងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្ដីពីការធានានិរន្តរភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | - |
| ៩ | សេចក្ដីណែនាំលេខ០១១ ស.ណ.ន. ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំរបាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តថ្មី | - |
| ១០ | សេចក្ដីណែនាំលេខ០១៨ ស.ណ.ន. ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីបែបបទនិងនីតិវិធីនៃការផ្ដល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ | - |
| ១១ | សេចក្ដីណែនាំលេខ០៣២ ស.ណ.ន. ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីគំរូបទបញ្ជាផ្ទៃក្នុងថ្មីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ | - |

| ល.រ. | លិខិតបទដ្ឋានគតិយុត្ត | ផ្សេងៗ |
|---|---|---|
| ១២ | សេចក្តីណែនាំលេខ០៤៥ ស.ណ.ន. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការជ្រើសរើសតំណាងយុវជនចូលរួមជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ | - |
| ១៣ | សេចក្តីណែនាំលេខ១៦៧/២២ មស-ស.ណ.ន. ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ របស់ក្រសួងមុខងារសាធារណៈ ស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលរាជធានី និងរដ្ឋបាលខណ្ឌ | - |
| ១៤ | សេចក្តីណែនាំលេខ១៦៨/២២ មស-ស.ណ.ន. ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ របស់ក្រសួងមុខងារសាធារណៈ ស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិក រដ្ឋបាលក្រុង ស្រុក | - |
| ១៥ | ព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ | ឆ្នាំ ២០២៣ |
| ១៦ | ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ២០២៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម | - |
| ១៧ | ព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ២០២៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ | - |
| ១៨ | ព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ | - |
| ១៩ | សារាចរអន្តរក្រសួងលេខ០០៨ សហវ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃស្តីពីកែសម្រួលឯកសារធនធានថវិកាពីមូលនិធិឃុំ សង្កាត់ ទៅរដ្ឋបាលឃុំ សង្កាត់ និងពីមូលនិធិក្រុង ស្រុកទៅរដ្ឋបាលក្រុង ស្រុក | - |
| ២០ | សារាចរណែនាំបន្ថែមលេខ០១២ សហវ-សរ.អរតន ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការស្នើនលិខិតយុត្តាធិការចំណាយសម្រាប់មុខសញ្ញាចំណាយថវិកាក្នុងក្របខណ្ឌរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់តាមប្រព័ន្ធេកសារឌីជីថល(FMIS Portal) | - |
| ២១ | សារាចរអន្តរក្រសួងលេខ០០៧ សហវ-សរ.អហក. ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសវាសង្គម និងអនាម័យ បរិស្ថាន និងមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ | - |
| ២២ | អនុក្រឹត្យលេខ៧៦ អនក្រ.បក. ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈនិងការពិពណ៌នាមុខតំណែងនានាក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ | - |
| ២៣ | អនុក្រឹត្យលេខ១៥២ អនក្រ.បក. ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ខណ្ឌ | - |
| ២៤ | អនុក្រឹត្យលេខ១៥៣ អនក្រ.បក. ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ | - |

| ល.រ. | លិខិតបទដ្ឋានគតិយុត្ត | ផ្សេងៗ |
|---|---|---|
| ២៥ | អនុក្រឹត្យលេខ១៥៤ អនក្រ.បក. ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន | - |
| ២៦ | អនុក្រឹត្យលេខ២០២ អនក្រ.បក. ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គមនិងសិទ្ធិជាមូលដ្ឋាន | - |
| ២៧ | អនុក្រឹត្យលេខ២១៣ អនក្រ.បក. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | - |
| ២៨ | អនុក្រឹត្យលេខ២៨០ អនក្រ.បក. ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការលក្ខខណ្ឌបែបបទនិងនីតិវិធីនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត | - |
| ២៩ | អនុក្រឹត្យលេខ៣២៩ អនក្រ.បក. ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការអនុវត្តកម្មវិធីជាតិសង្គមផ្នែកបណ្ដុះបណ្ដាលវិជ្ជាជីវៈនិងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ | - |
| ៣០ | ប្រកាសអន្តរក្រសួងលេខ០៧៤ ប្រក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ដីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្ដីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | - |
| ៣១ | ប្រកាសលេខ១៨០ សហវ.ប្រក.អហក. ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ | - |
| ៣២ | ប្រកាសលេខ៩៣១ ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការបង្កើតក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ | - |
| ៣៣ | សេចក្ដីណែនាំលេខ០០១ ស.ណ.ន. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំរបាយការណ៍អនុវត្តការងាររបស់រដ្ឋបាលរាជធានី | - |
| ៣៤ | សេចក្ដីណែនាំលេខ០០២ ស.ណ.ន. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំរបាយការណ៍អនុវត្តការងាររបស់រដ្ឋបាលខេត្ត | - |
| ៣៥ | សេចក្ដីណែនាំលេខ០០៣ ស.ណ.ន. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំរបាយការណ៍អនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក | - |
| ៣៦ | សេចក្ដីណែនាំលេខ០០៤ ស.ណ.ន. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំរបាយការណ៍អនុវត្តការងាររបស់រដ្ឋបាលខណ្ឌ | - |
| ៣៧ | សេចក្ដីណែនាំលេខ០០៥ ស.ណ.ន. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំរបាយការណ៍អនុវត្តការងាររបស់រដ្ឋបាលឃុំ សង្កាត់ | - |
| ៣៨ | សេចក្ដីណែនាំលេខ០៣៧ ស.ណ.ន. ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការពង្រឹងចលនាប្រជាការពារ | - |
| ៣៩ | សេចក្ដីណែនាំលេខ៥៨ អយក-ស.ណ.ន. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីការដំណើរការគ្រឹះស្ថានមត្តេយ្យសិក្សានិងសេវាអប់រំកុមារតូច ឆ្នាំ២០២៣-២០២៤ ក្នុងក្របខណ្ឌស្តង់ដាសាលារៀនគំរូ | - |

| ល.រ. | លិខិតបទដ្ឋានគតិយុត្ត | ផ្សេងៗ |
|---|---|---|
| ៤០ | សេចក្តីណែនាំលេខ៥៩ អយក-ស.ណ.ន. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការដំណើរការគ្រឹះស្ថានមត្តេយ្យសិក្សានិងសេវាអប់រំកុមារតូច ឆ្នាំ២០២៣-២០២៤ ក្នុងក្របខណ្ឌស្តង់ដាសាលារៀនគំរូ | - |
| ៤១ | សេចក្តីណែនាំលេខ៦០ អយក-ស.ណ.ន. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការដំណើរការគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ ឆ្នាំ២០២៣-២០២៤ ក្នុងក្របខណ្ឌស្តង់ដាសាលារៀនគំរូ | - |
| ៤២ | អនុក្រឹត្យលេខ០៤ អនក្រ.បក. ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ ស្តីពីការដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា | ឆ្នាំ ២០២៤ |
| ៤៣ | អនុក្រឹត្យលេខ១០ អនក្រ.បក. ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ | - |
| ៤៤ | អនុក្រឹត្យលេខ៨៤ អនក្រ.បក. ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ ស្តីពីការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាជពលរដ្ឋរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក ខណ្ឌ | - |
| ៤៥ | អនុក្រឹត្យលេខ២៤៩ អនក្រ.បក. ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកំណត់អត្រាចែករំលែកពីសេវាសាធារណៈនិងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋពីរដ្ឋបាលថ្នាក់ជាតិជូនជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ | - |
| ៤៦ | អនុក្រឹត្យលេខ២៨០ អនក្រ.បក. ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការគោលការណ៍និងបទបញ្ញត្តិនៃការកំណត់លេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជណាចក្រកម្ពុជា | - |
| ៤៧ | ប្រកាសអន្តរក្រសួងលេខ០៧៤ ប្រក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | - |
| ៤៨ | សេចក្តីសម្រេចលេខ៤៤៩៩ ស.ស.រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការរៀបចំនិងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ | - |
| ៤៩ | សេចក្តីសម្រេចលេខ០០៩ ស.ស.រ./គ.ជ.អ.ប. ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំប្រតិបត្តិស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់អ្នកផ្តត់ផ្គង់ | - |
| ៥០ | សេចក្តីណែនាំលេខ០០៦ ស.ណ.ន. ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ ស្តីពី បែបបទនិងនីតិនៃការកែតម្រូវទិន្នន័យនិងមោឃភាពបញ្ជីអត្រានុកូល ដ្ឋាន | - |
| ៥១ | សេចក្តីណែនាំលេខ០០២ ស.ណ.ន. ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការអញ្ជើញនិងការជូនដំណឹងអំពីនៃការធ្វើអធិការកិច្ចឬអង្កេតស្រាវជ្រាវដោះស្រាយបណ្តឹង | - |

| ល.រ. | លិខិតបទដ្ឋានគតិយុត្ត | ផ្សេងៗ |
|---|---|---|
| ៥២ | សេចក្តីណែនាំលេខ០៤ ស.ណ.ន. ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈបញ្ជាការសន្តិសុខអចិន្ត្រៃសម្រាប់ការបោះឆ្នោត ស្តីពីកិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតឆ្នាំ២០២៤ ការអញ្ជើញ និងការជូនដំណឹងអំពីនៃការធ្វើអធិការកិច្ចឬអង្កេតស្រាវជ្រាវដោះស្រាយបណ្តឹង | - |
| ៥៣ | ប្រកាសអន្តរក្រសួងលេខ០៥២ ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការដាក់ឱ្យប្រើលេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិនៃព្រះរាជាណាចក្រកម្ពុជា | ឆ្នាំ ២០២៥ |
| ៥៤ | សេចក្តីណែនាំលេខ៧២២១ អ.រត.ន. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់មាតិកាថវិកានិងលិខិតយុត្តាធិការចំណាយសម្រាប់ទូទាត់ថវិកាសេវាសង្គម និងអនាម័យបរិស្ថានទៅរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ | - |

# ឧបសម្ព័ន្ធទី២៖ ភូមិដែលត្រូវបានបង្កើតថ្មីក្នុងអាណត្តិទី៥ នៃក្រុមប្រឹក្សាឃុំ សង្កាត់

| ល.រ | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | ភូមិ | ឆ្នាំ |
|---|---|---|---|---|---|
| ១ | កំពង់ចាម | ចំការលើ | តាអុង | អំពិលជួរ | ២០២២ |
| ២ | កំពង់ចាម | ចំការលើ | សំព័រ | ធាំធា | ២០២២ |
| ៣ | កំពង់ចាម | ចំការលើ | ស្វាយទាប | ថ្នល់បែកជើង | ២០២២ |
| ៤ | កំពង់ចាម | ចំការលើ | ស្វាយទាប | ថ្នក់បត់ | ២០២២ |
| ៥ | កំពង់ចាម | ចំការលើ | ស្វាយទាប | បុស្សចេកព្រៃ | ២០២២ |
| ៦ | កំពង់ចាម | ចំការលើ | បុសខ្នុរ | ភូមិបាំង១ | ២០២២ |
| ៧ | កំពង់ចាម | ចំការលើ | បុសខ្នុរ | ភូមិបាំង២ | ២០២២ |
| ៨ | កំពង់ចាម | ចំការលើ | បុសខ្នុរ | បុសខ្នុរលើ | ២០២២ |
| ៩ | កំពង់ចាម | ចំការលើ | បុសខ្នុរ | ១០មករាលើ | ២០២២ |
| ១០ | កំពង់ចាម | ចំការលើ | ជ័យយោ | ជ័យយោត្បូង | ២០២២ |
| ១១ | កំពង់ចាម | ចំការលើ | ជ័យយោ | អកមោក | ២០២២ |
| ១២ | កំពង់ចាម | ចំការលើ | តាប្រុក | តាប៉ាង១ | ២០២២ |
| ១៣ | កំពង់ចាម | ចំការលើ | តាប្រុក | តាប៉ាង២ | ២០២២ |
| ១៤ | កំពង់ចាម | ចំការលើ | តាប្រុក | តាប៉ាង៣ | ២០២២ |
| ១៥ | កំពង់ចាម | ចំការលើ | តាប្រុក | តាប៉ាង៤ | ២០២២ |
| ១៦ | កំពង់ចាម | កំពង់ចាម | បឹងកុក | បឹងកុកទី៣ | ២០២៣ |
| ១៧ | កំពង់ចាម | កំពង់ចាម | វាលវង់ | ទី៦ «ក» | ២០២៣ |
| ១៨ | កំពង់ចាម | កោះសុទិន | កោះសុទិន | ទី១៥ | ២០២៣ |
| ១៩ | កំពង់ចាម | កងមាស | សូរគង | បឹងត្រាវត្បូង | ២០២៣ |
| ២០ | កំពង់ចាម | កងមាស | សូរគង | បឹងត្រាវជើង | ២០២៣ |
| ២១ | កំពង់ចាម | កងមាស | សូរគង | ព្រៃកគ្រួសកើត | ២០២៣ |
| ២២ | កំពង់ចាម | កងមាស | សូរគង | ព្រៃកគ្រួសលិច | ២០២៣ |
| ២៣ | កំពង់ចាម | កងមាស | រាយប៉ាយ | ទួលបី១ | ២០២៣ |
| ២៤ | កំពង់ចាម | កងមាស | រាយប៉ាយ | ទួលបី២ | ២០២៣ |
| ២៥ | កំពង់ចាម | កងមាស | រាយប៉ាយ | ពោធិ៍មានជ័យ | ២០២៣ |
| ២៦ | កំពង់ចាម | កងមាស | រាយប៉ាយ | រាយប៉ាយកណ្តាល | ២០២៣ |
| ២៧ | កំពង់ចាម | បាធាយ | តាំងក្រសាំង | ព្រះវិហារ | ២០២៣ |
| ២៨ | កំពង់ចាម | បាធាយ | ជើងព្រៃ | ស្រះតាប៉ែន | ២០២៣ |
| ២៩ | កំពង់ចាម | បាធាយ | សណ្តែក | គ្រពាំងចក | ២០២៣ |
| ៣០ | កំពង់ចាម | បាធាយ | សណ្តែក | បន្ទាយចាស់ | ២០២៣ |
| ៣១ | កំពង់ចាម | បាធាយ | សណ្តែក | កកោះ | ២០២៣ |

| ល.រ | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | ទួមិ | ឆ្នាំ |
|---|---|---|---|---|---|
| ៣២ | កំពង់ចាម | បាធាយ | សណ្ដែក | ជុំម្សៅ | ២០២៣ |
| ៣៣ | កំពង់ចាម | បាធាយ | សំបូរ | តាពន់ | ២០២៣ |
| ៣៤ | កំពង់ចាម | បាធាយ | សំបូរ | ត្រពាំងថ្លា | ២០២៣ |
| ៣៥ | កំពង់ចាម | បាធាយ | ផ្អាវ | ផ្សារផ្អាវ | ២០២៣ |
| ៣៦ | កំពង់ចាម | ស្ទឹងត្រង់ | អារក្សត្នោត | ល្វា១ | ២០២៣ |
| ៣៧ | កំពង់ចាម | ស្ទឹងត្រង់ | អារក្សត្នោត | ល្វា២ | ២០២៣ |
| ៣៨ | កំពង់ចាម | ស្ទឹងត្រង់ | អារក្សត្នោត | បែកអន្លង់១ | ២០២៣ |
| ៣៩ | កំពង់ចាម | ស្ទឹងត្រង់ | អារក្សត្នោត | បែកអន្លង់២ | ២០២៣ |
| ៤០ | កំពង់ចាម | ស្ទឹងត្រង់ | ព្រែកបាក់ | ព្រែកបាក់១ | ២០២៣ |
| ៤១ | កំពង់ចាម | ស្ទឹងត្រង់ | ព្រែកបាក់ | ព្រែកបាក់២ | ២០២៣ |
| ៤២ | កំពង់ចាម | ស្ទឹងត្រង់ | ព្រែកកក់ | បឹងដែង១ | ២០២៣ |
| ៤៣ | កំពង់ចាម | ស្ទឹងត្រង់ | ព្រែកកក់ | បឹងដែង២ | ២០២៣ |
| ៤៤ | កំពង់ចាម | កំពង់សៀម | អំពិល | សណ្ដាន | ២០២៣ |
| ៤៥ | កំពង់ចាម | កំពង់សៀម | អំពិល | នគរបាជ័យ | ២០២៣ |
| ៤៦ | កំពង់ចាម | កំពង់សៀម | ស្រក | តាម៉ៅ | ២០២៤ |
| ៤៧ | បន្ទាយមានជ័យ | ម៉ាឡៃ | ទួលពង្រ | បឹងជម្រុកតេជោ ឈ្នះ-ឈ្នះ | ២០២២ |
| ៤៨ | បន្ទាយមានជ័យ | ភ្នំស្រុក | ភ្នំដី | កំពឹងពួយមួយ | ២០២២ |
| ៤៩ | បន្ទាយមានជ័យ | ភ្នំស្រុក | ភ្នំដី | ពន្លៃត្បូង | ២០២២ |
| ៥០ | បន្ទាយមានជ័យ | ម៉ាឡៃ | ទួលពង្រ | បឹង៧៥តេជោ ឈ្នះ-ឈ្នះ | ២០២៤ |
| ៥១ | បន្ទាយមានជ័យ | ម៉ាឡៃ | ទួលពង្រ | ម៉ក់ហឺន | ២០២៤ |
| ៥២ | បន្ទាយមានជ័យ | ម៉ាឡៃ | ទួលពង្រ | ភ្នំដូនសម | ២០២៤ |
| ៥៣ | បន្ទាយមានជ័យ | ម៉ាឡៃ | តាគង់ | ដំណាក់ថ្មី | ២០២៦ |
| ៥៤ | បន្ទាយមានជ័យ | ម៉ាឡៃ | តាគង់ | បុស្សធំ | ២០២៦ |
| ៥៥ | បន្ទាយមានជ័យ | ភ្នំស្រុក | ប៉ោយចារ | តេជោសន្តិភាព | ២០២៦ |
| ៥៦ | បន្ទាយមានជ័យ | ស្វាយចេក | ស្លក្រាម | រង់ចាំ១ | ២០២៦ |
| ៥៧ | បន្ទាយមានជ័យ | ស្វាយចេក | ស្លក្រាម | រង់ចាំ២ | ២០២៦ |
| ៥៨ | បន្ទាយមានជ័យ | ស្វាយចេក | ស្លក្រាម | រង់ចាំ៣ | ២០២៦ |
| ៥៩ | បន្ទាយមានជ័យ | ស្វាយចេក | ស្លក្រាម | រង់ចាំ៤ | ២០២៦ |
| ៦០ | បន្ទាយមានជ័យ | ស្វាយចេក | ស្លក្រាម | រង់ចាំ៥ | ២០២៦ |
| ៦១ | បន្ទាយមានជ័យ | ស្វាយចេក | ស្លក្រាម | រង់ចាំ៦ | ២០២៦ |

| ល.រ | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | ទួមិ | ឆ្នាំ |
|---|---|---|---|---|---|
| ៦២ | កំពត | ជុំគិរី | ច្រេស | បាក់នឹម | ២០២២ |
| ៦៣ | កំពត | ជុំគិរី | ជំពូវន្ត | ត្រពាំងព្រីង | ២០២២ |
| ៦៤ | កំពត | កំពង់ត្រាច | បឹងសាលា ខាងត្បូង | អន្លង់ព្រីង | ២០២២ |
| ៦៥ | ត្បូងឃ្មុំ | មេមត់ | ដារ | បុរីតេជោសែនលិច | ២០២២ |
| ៦៦ | ត្បូងឃ្មុំ | មេមត់ | ដារ | បុរីតេជោសែនកើត | ២០២២ |
| ៦៧ | ព្រៃវែង | ស៊ីធរកណ្តាល | ឫស្សីសាញ់ | ព្រៃឈៀងទី១ | ២០២២ |
| ៦៨ | ព្រៃវែង | ស៊ីធរកណ្តាល | ឫស្សីសាញ់ | ព្រៃឈៀងទី២ | ២០២២ |
| ៦៩ | ព្រៃវែង | ស៊ីធរកណ្តាល | ឫស្សីសាញ់ | ព្រៃឈៀងទី៣ | ២០២២ |
| ៧០ | ព្រៃវែង | ស៊ីធរកណ្តាល | ឫស្សីសាញ់ | ព្រៃឈៀងទី៤ | ២០២២ |
| ៧១ | ព្រៃវែង | ពាមរក៍ | បាបោង | សុពម្រិតសីហនុ | ២០២២ |
| ៧២ | ព្រៃវែង | ពោធិ៍រៀង | ព្រែកអន្ទះ | ច្រាំងទទឹងលើ | ២០២២ |
| ៧៣ | ព្រៃវែង | ពោធិ៍រៀង | ព្រែកអន្ទះ | ច្រាំងទទឹងក្រោម | ២០២២ |
| ៧៤ | ព្រៃវែង | ពោធិ៍រៀង | កំពង់ឫស្សី | កំពង់ឫស្សីលើ | ២០២២ |
| ៧៥ | ព្រៃវែង | ពោធិ៍រៀង | កំពង់ឫស្សី | កំពង់ឫស្សីក្រោម | ២០២២ |
| ៧៦ | ព្រៃវែង | ពោធិ៍រៀង | កំពង់ឫស្សី | វាល | ២០២២ |
| ៧៧ | ព្រៃវែង | ពោធិ៍រៀង | ព្រែកជ្រៃ | អន្លង់ទ្រាជើង | ២០២២ |
| ៧៨ | ព្រៃវែង | ពោធិ៍រៀង | ព្រែកជ្រៃ | អន្លង់ទ្រាត្បូង | ២០២២ |
| ៧៩ | ព្រៃវែង | ពោធិ៍រៀង | ព្រែកតាសរ | ព្រែកផ្ទោល | ២០២២ |
| ៨០ | ព្រៃវែង | ពារាំង | កញ្ចំ | ជំទាវម៉ា | ២០២២ |
| ៨១ | ព្រៃវែង | ពារាំង | កញ្ចំ | បង់បត់ | ២០២២ |
| ៨២ | ព្រៃវែង | ពារាំង | កញ្ចំ | ទ្រាស្តៅ | ២០២២ |
| ៨៣ | ព្រៃវែង | ពារាំង | កំពង់ពពិល | បទសន្ទ្រាលើ | ២០២២ |
| ៨៤ | ព្រៃវែង | ពារាំង | កំពង់ពពិល | បទសន្ទ្រាក្រោម | ២០២២ |
| ៨៥ | ព្រៃវែង | ពារាំង | ព្រៃញ្ញោ | ព្រៃញ្ញោជើង | ២០២២ |
| ៨៦ | ព្រៃវែង | ពារាំង | ព្រៃញ្ញោ | ព្រៃញ្ញោកណ្តាល | ២០២២ |
| ៨៧ | ព្រៃវែង | ពារាំង | ព្រៃញ្ញោ | ព្រៃញ្ញោត្បូង | ២០២២ |
| ៨៨ | ព្រៃវែង | ពារាំង | ព្រៃញ្ញោ | ទួលត្បាល់ | ២០២២ |
| ៨៩ | ព្រៃវែង | ពារាំង | ព្រៃញ្ញោ | ព្រៃស្លាកើត | ២០២២ |
| ៩០ | ព្រៃវែង | ពារាំង | ព្រៃញ្ញោ | ព្រៃស្លាលិច | ២០២២ |
| ៩១ | ស្ទឹងត្រែង | ស្ទឹងត្រែង | ស្ទឹងត្រែង | ភ្នំជាតុ | ២០២២ |
| ៩២ | ស្ទឹងត្រែង | ស្ទឹងត្រែង | ស្ទឹងត្រែង | រាជានុកូល១ | ២០២២ |

| ល.រ | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | ទូមិ | ឆ្នាំ |
|---|---|---|---|---|---|
| ៩៣ | ស្ទឹងត្រែង | ស្ទឹងត្រែង | ស្ទឹងត្រែង | រាជានុកូល២ | ២០២២ |
| ៩៤ | ស្ទឹងត្រែង | ស្ទឹងត្រែង | ស្ទឹងត្រែង | អូរពង់មាន់១ | ២០២២ |
| ៩៥ | ស្ទឹងត្រែង | ស្ទឹងត្រែង | ស្ទឹងត្រែង | អូរពង់មាន់២ | ២០២២ |
| ៩៦ | ស្ទឹងត្រែង | ថាឡាបរិវ៉ាត់ | អន្លង់ជ្រៃ | អន្លង់ស្ពំ | ២០២២ |
| ៩៧ | ស្ទឹងត្រែង | ថាឡាបរិវ៉ាត់ | អូររៃ | ត្រពាំងធំ | ២០២២ |
| ៩៨ | ស្ទឹងត្រែង | ថាឡាបរិវ៉ាត់ | សំអាង | ត្នោតថ្មី | ២០២២ |
| ៩៩ | ស្ទឹងត្រែង | ថាឡាបរិវ៉ាត់ | សំអាង | ប្រឡាងខ្លង | ២០២២ |
| ១០០ | ក្រចេះ | ស្នួល | ឃ្សឹម | ដងរ៉ែក | ២០២២ |
| ១០១ | ក្រចេះ | ស្នួល | ឃ្សឹម | ត្រពាំងឈូក | ២០២២ |
| ១០២ | ក្រចេះ | ស្នួល | ស្វាយជ្រះ | សាមគ្គី | ២០២២ |
| ១០៣ | ក្រចេះ | ស្នួល | ស្វាយជ្រះ | វៀងជ័យ | ២០២២ |
| ១០៤ | ក្រចេះ | ស្នួល | ស្វាយជ្រះ | អូរបោះរបង | ២០២២ |
| ១០៥ | ក្រចេះ | ស្នួល | ស្វាយជ្រះ | អូរសាឡូង | ២០២២ |
| ១០៦ | ក្រចេះ | ស្នួល | ស្វាយជ្រះ | សំបួរសែនជ័យ | ២០២២ |
| ១០៧ | ក្រចេះ | ស្នួល | ២ធ្នូ | ជ្រៃម៉ាំង | ២០២២ |
| ១០៨ | ក្រចេះ | ស្នួល | ២ធ្នូ | ត្រពាំងស្បែក | ២០២២ |
| ១០៩ | ក្រចេះ | ស្នួល | ស្នួល | ផ្សារស្នួល | ២០២២ |
| ១១០ | ក្រចេះ | ស្នួល | ស្នួល | រោងចក្រ | ២០២២ |
| ១១១ | ក្រចេះ | ស្នួល | ស្នួល | ក្រសាំង | ២០២២ |
| ១១២ | ក្រចេះ | ស្នួល | ស្នួល | ត្រពាំងលាក់ | ២០២២ |
| ១១៣ | ក្រចេះ | ស្នួល | ស្រែចារ | អញ្ចាញ | ២០២២ |
| ១១៤ | ក្រចេះ | ស្នួល | ស្រែចារ | ដីប៉ែ | ២០២២ |
| ១១៥ | ក្រចេះ | ស្នួល | ស្រែចារ | បាត់ហើយ | ២០២២ |
| ១១៦ | ក្រចេះ | ស្នួល | ស្រែចារ | ស្រែចារ | ២០២២ |
| ១១៧ | ក្រចេះ | ស្នួល | ស្រែចារ | ដូនប៉ុក | ២០២២ |
| ១១៨ | ក្រចេះ | ស្នួល | ស្រែចារ | ដូនមាស១ | ២០២២ |
| ១១៩ | ក្រចេះ | ស្នួល | ស្រែចារ | ដូនមាស២ | ២០២២ |
| ១២០ | ក្រចេះ | ស្នួល | ស្រែចារ | ដូនមាស៣ | ២០២២ |
| ១២១ | ក្រចេះ | ស្នួល | ស្រែចារ | អូរតាញាន | ២០២២ |
| ១២២ | ក្រចេះ | ស្នួល | គ្រញូងសែនជ័យ | សែនអភិវឌ្ឍន៍ | ២០២២ |
| ១២៣ | ក្រចេះ | ស្នួល | គ្រញូងសែនជ័យ | គ្រញូង៣ | ២០២២ |
| ១២៤ | ក្រចេះ | ស្នួល | គ្រញូងសែនជ័យ | ១០៤ | ២០២២ |

| ល.រ | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | ទួមិ | ឆ្នាំ |
|---|---|---|---|---|---|
| ១២៥ | ក្រចេះ | ស្នួល | គ្រញូងសែនជ័យ | អូរចចារមានជ័យ | ២០២២ |
| ១២៦ | ក្រចេះ | ស្នួល | គ្រញូងសែនជ័យ | អូរសែនជ័យ | ២០២២ |
| ១២៧ | ក្រចេះ | ស្នួល | គ្រញូងសែនជ័យ | ការបួនសែនជ័យ | ២០២២ |
| ១២៨ | ក្រចេះ | ស្នួល | គ្រញូងសែនជ័យ | ប្រឹមប្រឹយ | ២០២២ |
| ១២៩ | ក្រចេះ | ឆ្លូង | ព្រែកសាម៉ាន់ | ត្រពាំងបេង | ២០២២ |
| ១៣០ | ក្រចេះ | ឆ្លូង | ព្រែកសាម៉ាន់ | ព្រែកសណ្ដាយ | ២០២២ |
| ១៣១ | ក្រចេះ | ឆ្លូង | ព្រែកសាម៉ាន់ | ស្រែផល | ២០២២ |
| ១៣២ | បាត់ដំបង | សំឡូត | ស៊ុង | អូររាំងខេន | ២០២២ |
| ១៣៣ | បាត់ដំបង | សំឡូត | កំពង់ល្ពៅ | ចំការស្រូវ | ២០២២ |
| ១៣៤ | បាត់ដំបង | សំឡូត | កំពង់ល្ពៅ | រទៀង | ២០២២ |
| ១៣៥ | បាត់ដំបង | សំឡូត | កំពង់ល្ពៅ | វាលចម្បាំង | ២០២២ |
| ១៣៦ | បាត់ដំបង | សំឡូត | មានជ័យ | អំពិលជួង | ២០២២ |
| ១៣៧ | បាត់ដំបង | សំឡូត | សំឡូត | វះជ័យ | ២០២២ |
| ១៣៨ | បាត់ដំបង | សំឡូត | សំឡូត | បរឡាង | ២០២២ |
| ១៣៩ | បាត់ដំបង | សំឡូត | សំឡូត | សាមគ្គី | ២០២២ |
| ១៤០ | បាត់ដំបង | សំឡូត | សំឡូត | សុខសាន្ត | ២០២២ |
| ១៤១ | បាត់ដំបង | សំឡូត | សំឡូត | ទួលពោធិ៍ | ២០២២ |
| ១៤២ | បាត់ដំបង | មោងឫស្សី | តាលាស់ | សាករ | ២០២២ |
| ១៤៣ | បាត់ដំបង | បវេល | បឹងប្រាំ | ដំណាក់តាស៊ុត | ២០២២ |
| ១៤៤ | បាត់ដំបង | បាណន់ | ចែងមានជ័យ | ប៉ៃឡាំ | ២០២៣ |
| ១៤៥ | បាត់ដំបង | រុក្ខគិរី | ព្រែកជីក | ព្រែកជីក១ | ២០២៣ |
| ១៤៦ | បាត់ដំបង | រុក្ខគិរី | ព្រែកជីក | ឆ្កែខាំប្រើស១ | ២០២៣ |
| ១៤៧ | ពោធិ៍សាត់ | ពោធិ៍សាត់ | ចំរើនផល | បរវង្ស | ២០២២ |
| ១៤៨ | ពោធិ៍សាត់ | ពោធិ៍សាត់ | ផ្ទះព្រៃ | ផ្ទះព្រៃ | ២០២២ |
| ១៤៩ | ពោធិ៍សាត់ | ពោធិ៍សាត់ | ផ្ទះព្រៃ | សំពៅមាស | ២០២២ |
| ១៥០ | ពោធិ៍សាត់ | ពោធិ៍សាត់ | ផ្ទះព្រៃ | ចំការចេក | ២០២២ |
| ១៥១ | ពោធិ៍សាត់ | ពោធិ៍សាត់ | រលាប | ថ្មបីដុំ | ២០២២ |
| ១៥២ | ពោធិ៍សាត់ | ពោធិ៍សាត់ | រលាប | អូរត្រាវ | ២០២២ |
| ១៥៣ | ពោធិ៍សាត់ | ពោធិ៍សាត់ | រលាប | ឈើទាលរូង | ២០២២ |
| ១៥៤ | ពោធិ៍សាត់ | កណ្ដៀង | កញ្ជរ | តាម៉ៅ | ២០២២ |
| ១៥៥ | ពោធិ៍សាត់ | កណ្ដៀង | កញ្ជរ | ប្រឡាយធំ | ២០២២ |
| ១៥៦ | ពោធិ៍សាត់ | បាកាន | ស្វាយដូនកែវ | ព្រាល | ២០២២ |

| ល.រ | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | ទូមិ | ឆ្នាំ |
|---|---|---|---|---|---|
| ១៥៧ | ពោធិ៍សាត់ | ក្រគរ | ក្បាលត្រាច | ស្រគំ | ២០២២ |
| ១៥៨ | ពោធិ៍សាត់ | ក្រគរ | ឈើតុំ | ក្រាំងខ្លឿន | ២០២២ |
| ១៥៩ | ពោធិ៍សាត់ | ក្រវ៉ាញ | ក្រវ៉ាញ | រគោ | ២០២២ |
| ១៦០ | ពោធិ៍សាត់ | ក្រវ៉ាញ | ក្រវ៉ាញ | អូរ | ២០២២ |
| ១៦១ | ពោធិ៍សាត់ | ក្រវ៉ាញ | ព្រងិល | ព្រៃអណ្ដូង | ២០២២ |
| ១៦២ | ពោធិ៍សាត់ | ក្រវ៉ាញ | ព្រងិល | ប៊ុនរ៉ានីសែនជ័យ ដំណាកទ្រយឹង | ២០២៤ |
| ១៦៣ | កំពង់ស្ពឺ | ថ្ពង | ប្រាំបីមុម | ក្រាំងស្វាយធំ | ២០២៣ |
| ១៦៤ | កំពង់ស្ពឺ | ឱរ៉ាល់ | ត្រពាំងជោ | ផ្តោច | ២០២៦ |
| ១៦៥ | កំពង់ស្ពឺ | ឱរ៉ាល់ | ត្រពាំងជោ | ក្រាំងត្បែង | ២០២៦ |
| ១៦៦ | កំពង់ស្ពឺ | ឱរ៉ាល់ | ត្រពាំងជោ | ចាន់ពីង | ២០២៦ |
| ១៦៧ | កំពង់ស្ពឺ | ឱរ៉ាល់ | ត្រពាំងជោ | ពោធិ៍មាន | ២០២៦ |
| ១៦៨ | កំពង់ស្ពឺ | ឱរ៉ាល់ | ត្រពាំងជោ | ស្រែកិន | ២០២៦ |
| ១៦៩ | ឧត្តរមានជ័យ | សំរោង | កូនក្រៀល | ប្រាសាទរៀង | ២០២៣ |
| ១៧០ | ឧត្តរមានជ័យ | សំរោង | កូនក្រៀល | អូរខ្ចៅ | ២០២៣ |
| ១៧១ | ឧត្តរមានជ័យ | សំរោង | កូនក្រៀល | គិរីវ័ន្តសែនជ័យ | ២០២៣ |
| ១៧២ | ឧត្តរមានជ័យ | សំរោង | បុស្សូរ | ប្រាសាទភ្នំដី | ២០២៣ |

**ឧបសម្ព័ន្ធទី៣៖**

## ថវិកាឃុំ សង្កាត់ ចាប់ពីឆ្នាំ២០០២-២០២៦

(គិតជាលានរៀល)

| ឆ្នាំ | សមាសធាតុរដ្ឋបាល រួមនឹងចំណាយមិនបានគ្រោងទុក | | សមាសធាតុអភិវឌ្ឍន៍ | សមាសធាតុសេវាសង្គមបរិស្ថាន | បន្ថែម១% | ពន្ធចែករំលែក (៦%) | សរុបរួមនៃថវិកា |
|---|---|---|---|---|---|---|---|
| 2002 | 13,848.17 | - | 16,839.74 | - | - | - | 30,687.91 |
| 2003 | 19,388.80 | - | 32,030.73 | - | - | - | 51,419.53 |
| 2004 | 19,333.33 | - | 38,666.67 | - | - | - | 58,000.00 |
| 2005 | 20,712.00 | - | 45,388.00 | - | - | - | 66,100.00 |
| 2006 | 24,645.20 | - | 53,168.80 | - | - | - | 77,814.00 |
| 2007 | 32,514.00 | - | 57,036.00 | - | - | - | 89,550.00 |
| 2008 | 32,836.22 | - | 60,188.78 | - | - | - | 93,025.00 |
| 2009 | 34,324.10 | - | 79,015.90 | - | - | - | 113,340.00 |
| 2010 | 38,648.74 | - | 110,000.26 | - | - | - | 148,649.00 |
| 2011 | 52,602.00 | - | 106,798.00 | - | - | - | 159,400.00 |
| 2012 | 52,737.00 | - | 129,253.00 | - | - | - | 181,990.00 |
| 2013 | 54,107.00 | - | 150,311.00 | - | - | - | 204,418.00 |
| 2014 | 105,230.00 | - | 132,036.00 | - | - | - | 237,266.00 |
| 2015 | 139,795.00 | - | 132,159.00 | - | - | - | 271,954.00 |
| 2016 | 185,119.24 | - | 123,290.76 | - | - | - | 308,410.00 |
| 2017 | 227,603.00 | - | 147,801.00 | - | - | - | 375,404.00 |
| 2018 | 264,649.00 | - | 169,392.00 | - | - | 9,120.00 | 443,161.00 |
| 2019 | 309,635.00 | - | 214,165.00 | - | - | 13,514.00 | 537,314.00 |
| 2020 | 347,140.00 | - | 260,246.00 | - | 195,931.00 | 41,095.00 | 844,412.00 |
| 2021 | 351,469.00 | | 189,139.00 | - | 168,940.00 | 40,430.00 | 749,978.00 |
| 2022 | 414,009.00 | 38,712.00 | 236,288.00 | - | 197,059.00 | 44,776.00 | 930,844.00 |
| 2023 | 455,131.00 | 19,117.00 | 298,218.00 | - | 221,573.00 | 71,630.00 | 1,065,669.00 |
| 2024 | 504,423.00 | 25,021.00 | 325,277.00 | 65,055.00 | 255,644.00 | 109,318.00 | 1,284,738.00 |
| 2025 | 515,073.80 | 29,711.20 | 357,205.00 | 107,287.00 | 288,365.00 | 0 | 1,297,642.00 |
| 2026 | 509,312.00 | 28,079.00 | 314,481.00 | 123,546.00 | 278,694.00 | 93,872.00 | 1,347,984.00 |
| **សរុប** | **4,724,285.60** | **140,640.20** | **3,778,394.64** | **295,888.00** | **1,606,206.00** | **533,073.00** | **10,969,169.44** |